# សត្តប្បករណាភិធម្ម



# សត្តប្បករណាភិធម្ម

សេចក្ដីប្រែ

សម្រាប់សូត្រ

ស្រី-អ៊ូ

រៀបរៀង

ការផ្សាយរបស់

បណ្ណាគារ ជឹង-ប៉ោហួត

លេខ ១៤០ វិថីព្រះបាទអង្គអេង ភ្នំពេញ

ព.ស. ២៥០៩ គ.ស. ១៩៦៦

បោះពុម្ពលើកទី ៤

ចំនួន ១.០០០ ក្បាល

ទាំងឡាយពីលោកហ្គី ឃុន សំរ៉ង ទស់ក្រសួងខ្មែរ ដើម្បី
តំកល់ទុកក្នុង Library of Cambodia កញ្ញា 2015

# អារម្ភកថា

សៀវភៅនេះ កាលពីឆ្នាំ ១៩៥០ ខ្ញុំបានបោះពុម្ព ជាពីរក្បាលគឺ ឈ្មោះ អភិធម្មមាតិកា ១, ឈ្មោះ ធប្បករណាភិធម្ម ១, ដល់មកឆ្នាំ ១៩៦៤ ខ្ញុំបង្រួមសៀវភៅទាំងពីរក្បាលនេះ បញ្ចូលមួយទៅវិញ, ហើយខ្ញុំឲ្យឈ្មោះថា "សត្តប្បករណាភិធម្ម" ព្រោះសំដែងអំពីអភិធម្មទាំង ៧ គម្ពីរ មានគម្ពីរធម្មសង្គណីជាដើម ។

មូលហេតុដែលនាំឲ្យខ្ញុំដកស្រង់ យកអភិធម្មទាំងនេះ មកប្រែជាសម្រាយទៀតនោះគឺ:

ដោយយល់ឃើញថា ពុទ្ធបរិស័ទក្នុងកម្ពុជរដ្ឋនេះ ចាប់រៀនសូត្ររេះតាំអភិធម្មទាំងនេះ ជាភាសាបាលីសុទ្ធ ជាយូរហើយមកហើយ តែនៅមិនទាន់បានដឹងសេចក្ដីប្រែនោះឡើយ ចំណែកខាងធម៌សម្រាប់សូត្រឯទៀតៗ មានប្រែជាសម្រាយហើយ ដូចមានក្នុងសៀវភៅអនុមោទនវិធីនិងសត្តបរិត្តជាដើម ត្រង់អភិធម្មនេះជាធម៌សម្រាប់សូត្រញឹកញយណាស់ តែមិនទាន់មានប្រែជាសម្រាយសម្រាប់សូត្រនៅឡើយ ។

ហេតុនេះហើយដែលនាំឲ្យខ្ញុំខានព្យាយាម រែករកពេលវេលាខ្លះមកប្រែធម៌ទាំងនេះដរាបដល់ចប់; កាលដែលខ្ញុំប្រែនោះបានយកភាណវារ-បាលី, អភិធម្មបិដកបាលី និងសេចក្ដីប្រែ ដែលក្រុមជំនុំប្រែព្រះត្រៃបិដកបានប្រែទាំងស្រៀងរួចហើយ ព្រមទាំងអដ្ឋកថានៃព្រះអភិធម្មនោះ មកមើល

ផ្សំជាជំនួយក្នុងការប្រែនោះ ។

ឯការប្រែគម្ពីរនេះ គឺប្រែតាមសម្ពន្ធបាលីសុទ្ធ ហើយមានធ្វើនយលក្ខណៈ យោងលេខមកដាក់ខាងក្រោម ពន្យល់តាមគន្ថដីកាខ្លះ ត្រង់សេចក្ដីណាដែលលំបាកស្ដាប់ ។

ម្យ៉ាងទៀត ត្រង់បាលីភាគចុង ដាក់ខ្ទង់បញ្ចប់ធម៌និមួយ ៗ ដែលមានវែងក្រាបក្រៀកពាំងគស់ មិនមានទំនងបាលីគម្ពីរដទៃ គឺជារបៀបរបស់លោកអ្នកប្រាជ្ញជាន់ដើម យូរយារណាស់មកហើយ លោករៀបរៀងទុកមក ដើម្បីឲ្យងាយចាំចប់ធម៌មួយៗប៉ុណ្ណោះ ម្ល៉ោះហើយបាលីនោះមានវិបត្តិប្រែប្រួល មិនសមនឹងតាមរបៀបវេយ្យាករណ៍ខ្លះ ខ្ញុំក៏បានកែតម្រូវសម្រួលឲ្យត្រូវតាមទំនងដើមឡើងវិញ ។

លុះខ្ញុំកែសម្រួលនឹងប្រែចប់ស្រេចហើយ បានយកទៅប្រគេនព្រះទេពសត្ថា (ស៊ូ-ហាយ) និងព្រះគ្រូសិរីសោភ័ណ (ម៉ម-គួរ) ក្រុមជំនុំប្រែព្រះត្រៃបិដកឲ្យលោកជួយត្រួតពិនិត្យ លោកក៏ពេញចិត្តនឹងធម៌តាំងនេះដែរ បានចូលយោបល់ពិគ្រោះកែសម្រួល ដើម្បីឲ្យត្រឹមត្រូវតាមរបៀបនៃការប្រែបាលីផង ឲ្យស្រួលរៀនសូត្រផង ។

ទីបំផុតនេះ ខ្លួនព្រះបាទជាខ្ញុំ សូមខ្ញុំសូមថ្វាយដោយគោរព នូវបុញ្ញកុសលដែលជាលទ្ធផលកើតឡើងដោយសេចក្ដីព្យាយាម ប្រែធម៌តាំង

នេះនេះដំកល់ជាព្រះរាជកុសល:

- ថ្វាយចំពោះសម្តេចព្រះមហាក្សត្រិយានីជាអម្ចាស់ជីវិតលើត្បូងជាព្រះមាតាជាតិ,

- ថ្វាយចំពោះសម្តេចសហជីវិនព្រះប្រមុខរដ្ឋព្រះបិតាឯករាជជាតិ, សូមព្រះអង្គបានប្រកបដោយព្រះបរមសុខ សុភមង្គលគ្រប់ចំពូក កុំបីឃ្លៀងឃ្លាតឡើយ ។

ខ្ញុំសូមរំលែកកុសលដែលកើតអំពីសេចក្តីព្យាយាម ប្រែគម្ពីរទាំងនេះ ចែកជូនដល់ពុទ្ធបរិសទទាំងឡាយ ដែលពេញចិត្តនឹងគម្ពីរទាំងនេះ សូមឲ្យបានសេចក្តីសុខក្សេមក្សាន្តគ្រប់ប្រការ កុំបីឃ្លាតឡើយ ។

ឃុនសិរីមេធី ស្រី-អ៊ូ

ថ្ងៃសៅរ៍ ១០កើត ខែអស្សុជ ឆ្នាំខាលទោស័ក

ព.ស. ២៤៩៣

ត្រូវនឹងថ្ងៃទី ២១ ខែតុលា គ.ស. ១៩៥០

បោះពុម្ពលើកទី ២ ។

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស (បីដង) ។

*សូមនមស្ការចំពោះព្រះដ៏មានព្រះភាគ ជាអរហន្តសម្មាសម្ពុទ្ធ ព្រះអង្គនោះ (ដោយគោរព) ។*

---

## តិកមាតិកា

១) កុសលា ធម្មា អកុសលា ធម្មា អព្យាកតា ធម្មា *ធម៌ទាំងឡាយជាកុសល(១) ធម៌ទាំងឡាយជាអកុសល(២) ធម៌ទាំងឡាយជាអព្យាក្រឹត(៣)*

២) សុខាយ វេទនាយ សម្បយុត្តា ធម្មា ទុក្ខាយ វេទនាយ សម្បយុត្តា ធម្មា អទុក្ខមសុខាយ វេទនាយ សម្បយុត្តា ធម្មា *ធម៌ទាំងឡាយប្រកបដោយវេទនាជាសុខ ធម៌ទាំងឡាយប្រកបដោយវេទនាជាទុក្ខ ធម៌ទាំងឡាយប្រកបដោយវេទនា មិនមែនជាទុក្ខ មិនមែនជាសុខ*

---

*១- កុសលក្នុងភូមិ ៤ គឺ កាមាវចរភូមិ ១, រូបាវចរភូមិ ១, អរូបាវចរភូមិ ១, លោកុត្តរភូមិ ១, ។ ២- អកុសលចិត្តុប្បាទ ១២ ។ ៣- វិបាកក្នុងភូមិ ៤ កិរិយាព្យាក្រឹតក្នុងភូមិ ៣, រូប, និព្វាន ។*

៣) វិបាកា ធម្មា វិបាកធម្មធម្មា នេវវិបាកនវិបាកធម្មធម្មា ធម៌ទាំងឡាយជាវិបាក ធម៌ទាំងឡាយមានវិបាកជាប្រក្រតី ធម៌ទាំងឡាយមិនមែនជាវិបាក ទាំងមិនមែនមានវិបាកជាប្រក្រតី

៤) ឧបាទិន្នុបាទានិយា ធម្មា អនុបាទិន្នុបាទានិយា ធម្មា អនុបាទិន្នានុបាទានិយា ធម្មា ធម៌ទាំងឡាយដែលកម្មប្រកបដោយកិលេសមានតណ្ហាជាដើមកាន់យកហើយ ទាំងជាប្រយោជន៍ដល់ឧបាទាន ធម៌ទាំងឡាយដែលមិនមានកម្មប្រកបដោយកិលេសមានតណ្ហាជាដើមកាន់យកហើយ តែជាប្រយោជន៍ដល់ឧបាទាន (១) ធម៌ទាំងឡាយដែលមិនមានកម្មប្រកបដោយកិលេស មានតណ្ហាជាដើមកាន់យកហើយ ទាំងមិនមែនជាប្រយោជន៍ដល់ឧបាទាន

៥) សង្កិលិដ្ឋសង្កិលេសិកា ធម្មា អសង្កិលិដ្ឋសង្កិលេសិកា ធម្មា អសង្កិលិដ្ឋាសង្កិលេសិកា ធម្មា ធម៌ទាំងឡាយដែលសៅហ្មង ទាំងគួរដល់នូវសេចក្ដីសៅហ្មង ធម៌ទាំងឡាយដែលមិនសៅហ្មង តែគួរដល់នូវសេចក្ដីសៅហ្មង ធម៌ទាំងឡាយដែលមិនសៅហ្មង ទាំងមិនគួរដល់នូវសេចក្ដីសៅហ្មង

---

១- សេចក្ដីប្រកាន់មាំ ។

៦) សវិតក្កសវិចារា ធម្មា អវិតក្កវិចារមត្តា ធម្មា អវិតក្កាវិចារា ធម្មា ធម៌ទាំងឡាយប្រព្រឹត្តទៅជាមួយនឹងវិតក្កៈ ទាំងប្រព្រឹត្តទៅជាមួយនឹងវិចារៈ ធម៌ទាំងឡាយមិនមានវិតក្កៈ មានត្រឹមតែវិចារៈ ធម៌ទាំងឡាយមិនមានវិតក្កៈ ទាំងមិនមានវិចារៈ

៧) បីតិសហគតា ធម្មា សុខសហគតា ធម្មា ឧបេក្ខាសហគតា ធម្មា ធម៌ទាំងឡាយប្រកបដោយបីតិ ធម៌ទាំងឡាយប្រកបដោយសុខ ធម៌ទាំងឡាយប្រកបដោយឧបេក្ខា

៨) ទស្សនេន បហាតព្វា ធម្មា ភាវនាយ បហាតព្វា ធម្មា នេវ ទស្សនេន ន ភាវនាយ បហាតព្វា ធម្មា ធម៌ទាំងឡាយដែលត្រូវលះ ដោយទស្សនៈ(១) ធម៌ទាំងឡាយដែលត្រូវលះ ដោយភាវនា(២) ធម៌ទាំងឡាយដែលមិនត្រូវលះ ដោយទស្សនៈ ទាំងមិនត្រូវលះ ដោយភាវនា

៩) ទស្សនេន បហាតព្វហេតុកា ធម្មា ភាវនាយ បហាតព្វហេតុកា ធម្មា នេវ ទស្សនេន ន ភាវនាយ

---

១– ការឃើញគឺសំដៅយកសោតាបត្តិមគ្គ ។ ២– ការចំរើន សំដៅយក សកទាគាមិមគ្គ, អនាគាមិមគ្គ, អរហត្តមគ្គ ។

បហាតព្វហេតុកា ធម្មា ធម៌ទាំងឡាយមានហេតុដែលត្រូវលះដោយទស្សនៈ ធម៌ទាំងឡាយមានហេតុដែលត្រូវលះដោយភាវនា ធម៌ទាំងឡាយមានហេតុដែលមិនត្រូវលះ ដោយទស្សនៈ ទាំងមិនត្រូវលះដោយភាវនា

១០) អាចយគាមិនោ ធម្មា អបចយគាមិនោ ធម្មា នេវាចយគាមិនោ នាបចយគាមិនោ ធម្មា ធម៌ទាំងឡាយដល់នូវការសន្សំកពូនឡើងដោយកម្មកិលេស ធម៌ទាំងឡាយមិនដល់នូវការសន្សំកពូនឡើងដោយកម្មកិលេស ធម៌ទាំងឡាយមិនមែនដល់នូវការសន្សំកពូនឡើង ទាំងមិនមែនជាមិនដល់នូវការសន្សំកពូនឡើងដោយកម្មកិលេស

១១) សេក្ខា ធម្មា អសេក្ខា ធម្មា នេវសេក្ខា នា-សេក្ខា ធម្មា ធម៌ទាំងឡាយជារបស់សេក្ខបុគ្គល ធម៌ទាំងឡាយជារបស់អសេក្ខបុគ្គល ធម៌ទាំងឡាយមិនមែនជារបស់សេក្ខបុគ្គល ទាំងមិនមែនជារបស់អសេក្ខបុគ្គល

១២) បរិត្តា ធម្មា មហគ្គតា ធម្មា អប្បមាណា ធម្មា ធម៌ទាំងឡាយមានសភាពដ៏តូចឆ្មារ ធម៌ទាំងឡាយដល់នូវសភាពដ៏ធំ ធម៌ទាំងឡាយមានប្រមាណមិនបាន

១៣) បរិត្តារម្មណា ធម្មា មហគ្គតារម្មណា ធម្មា អប្បមាណារម្មណា ធម្មា ធម៌ទាំងឡាយមានអារម្មណ៍ដ៏តូចឆ្មារ ធម៌ទាំងឡាយមានអារម្មណ៍ដល់នូវសភាពធំ ធម៌ទាំងឡាយមានអារម្មណ៍ប្រមាណមិនបាន

១៤) ហីនា ធម្មា មជ្ឈិមា ធម្មា បណីតា ធម្មា ធម៌ទាំងឡាយថោកទាប ធម៌ទាំងឡាយជាកណ្ដាល ធម៌ទាំងឡាយដ៏ឧត្ដម

មិច្ឆត្តនិយតា ធម្មា សម្មត្តនិយតា ធម្មា អនិយតា ធម្មា ធម៌ទាំងឡាយមានសភាពដ៏ខុសនឹងទៀង ធម៌ទាំងឡាយមានសភាពដ៏ត្រូវនឹងទៀង ធម៌ទាំងឡាយមិនទៀង

១៦) មគ្គារម្មណា ធម្មា មគ្គហេតុកា ធម្មា មគ្គាធិបតិនោ ធម្មា ធម៌ទាំងឡាយមានមគ្គជាអារម្មណ៍ ធម៌ទាំងឡាយមានមគ្គជាហេតុ ធម៌ទាំងឡាយមានមគ្គជាអធិបតី

១៧) ឧប្បន្នា ធម្មា អនុប្បន្នា ធម្មា ឧប្បាទិនោ ធម្មា ធម៌ទាំងឡាយដែលកើតឡើងហើយ ធម៌ទាំងឡាយដែលមិនទាន់កើតឡើង ធម៌ទាំងឡាយដែលប្រុងនឹងកើតឡើង

១៨) អតីតា ធម្មា អនាគតា ធម្មា បច្ចុប្បន្នា ធម្មា ធម៌

ទាំងឡាយជាអតីត ធម៌ទាំងឡាយជាអនាគត ធម៌ទាំងឡាយជាបច្ចុប្បន្ន

១៩) អតីតារម្មណា ធម្មា អនាគតារម្មណា ធម្មា បច្ចុប្បន្នារម្មណា ធម្មា ធម៌ទាំងឡាយមានអារម្មណ៍ជាអតីត ធម៌ទាំងឡាយមានអារម្មណ៍ជាអនាគត ធម៌ទាំងឡាយមានអារម្មណ៍ជាបច្ចុប្បន្ន

២០) អជ្ឈត្តា ធម្មា ពហិទ្ធា ធម្មា អជ្ឈត្តពហិទ្ធា ធម្មា ធម៌ទាំងឡាយជាខាងក្នុង ធម៌ទាំងឡាយជាខាងក្រៅ ធម៌ទាំងឡាយជាខាងក្នុងនិងខាងក្រៅ

២១) អជ្ឈត្តារម្មណា ធម្មា ពហិទ្ធារម្មណា ធម្មា អជ្ឈត្តពហិទ្ធារម្មណា ធម្មា ធម៌ទាំងឡាយមានអារម្មណ៍ជាខាងក្នុង ធម៌ទាំងឡាយមានអារម្មណ៍ជាខាងក្រៅ ធម៌ទាំងឡាយមានអារម្មណ៍ជាខាងក្នុង និងខាងក្រៅ

២២) សនិទស្សនសប្បដិឃា ធម្មា អនិទស្សនសប្បដិឃា ធម្មា អនិទស្សនាប្បដិឃា ធម្មា ធម៌ទាំងឡាយប្រកបដោយការឃើញនិងប្រកបដោយការប៉ះពាល់ ធម៌ទាំងឡាយមិនប្រកបដោយការឃើញតែប្រកបដោយការប៉ះពាល់ ធម៌ទាំងឡាយមិនប្រកបដោយការឃើញទាំងមិនប្រកបដោយការប៉ះពាល់ ។

# ពាវីសតិ តិកមាតិកា ធម្មសង្គណិប្បករណ៍ តាម សមត្ថ

*គម្ពីរឈ្មោះធម្មសង្គណីដែលមានមាតិកា ២២ ចប់តែប៉ុណ្ណេះ ។*

---

## ទុកមាតិកា

១) ហេតូ ធម្មា ន ហេតូ ធម្មា *ធម៌ទាំងឡាយជាហេតុ(១)- ធម៌ទាំងឡាយមិនមែនជាហេតុ*

២) សហេតុកា ធម្មា អហេតុកា ធម្មា *ធម៌ទាំងឡាយប្រព្រឹត្តទៅជាមួយនឹងហេតុ ធម៌ទាំងឡាយមិនប្រព្រឹត្តទៅជាមួយនឹងហេតុ*

៣) ហេតុសម្បយុត្តា ធម្មា ហេតុវិប្បយុត្តា ធម្មា *ធម៌ទាំងឡាយប្រកបដោយហេតុ ធម៌ទាំងឡាយប្រាសចាកហេតុ*

៤) ហេតូ ចេវ ធម្មា សហេតុកា ច សហេតុកា ចេវ ធម្មា ន ច ហេតូ *ធម៌ទាំងឡាយជាហេតុផង ប្រព្រឹត្តទៅមួយនឹងហេតុផង ធម៌ទាំងឡាយគ្រាន់តែប្រព្រឹត្តទៅជាមួយនឹងហេតុ តែមិនមែនជាហេតុ*

៥) ហេតូ ចេវ ធម្មា ហេតុសម្បយុត្តា ច ហេតុសម្បយុត្តា ចេវ ធម្មា ន ច ហេតូ *ធម៌ទាំងឡាយជាហេតុផង ប្រកបដោយហេតុផង*

---

*១- ឫសគល់ ឬជា មេហោបណ្ដាលឲ្យកើតផល ។*

ធម៌ទាំងឡាយៈគ្រាន់តែប្រកបដោយហេតុ តែមិនមែនជាហេតុ

៦) ន ហេតូ ខោ បន ធម្មា សហេតុកាបិ អហេតុកាបិ

ហេតុគោច្ឆកំ ធម៌ទាំងឡាយមិនមែនជាហេតុ តែប្រព្រឹត្តទៅជាមួយនឹងហេតុ ធម៌ទាំងឡាយមិនមែនជាហេតុផង មិនប្រព្រឹត្តទៅជាមួយនឹងហេតុផង

ចប់ក្នុងហេតុតែប៉ុណ្ណេះ ។

៧) សប្បច្ចយា ធម្មា អប្បច្ចយា ធម្មា ធម៌ទាំងឡាយប្រព្រឹត្តទៅជាមួយនឹងបច្ច័យ(១) ធម៌ទាំងឡាយ មិនមានបច្ច័យ

៨) សង្ខតា ធម្មា អសង្ខតា ធម្មា ធម៌ទាំងឡាយ មានបច្ច័យតាក់តែង ធម៌ទាំងឡាយមិនមានបច្ច័យតាក់តែង

៩) សនិទស្សនា ធម្មា អនិទស្សនា ធម្មា ធម៌ទាំងឡាយប្រកបដោយការឃើញ ធម៌ទាំងឡាយមិនប្រកបដោយការឃើញ

---

១ – បច្ច័យប្រែថាជាផែនអាស្រ័យ ហើយប្រព្រឹត្តទៅនៃផលគឺជាហេតុ នាំឲ្យកើតផល ដូចគ្នានឹងហេតុដែរ ។

១០) សប្បដិឃា ធម្មា អប្បដិឃា ធម្មា ធម៌ទាំងឡាយប្រកបដោយការប៉ះពាល់ ធម៌ទាំងឡាយមិនប្រកបដោយការប៉ះពាល់

១១) រូបិនោ ធម្មា អរូបិនោ ធម្មា ធម៌ទាំងឡាយមានរូប ធម៌ទាំងឡាយមិនមានរូប

១២) លោកិយា ធម្មា លោកុត្តរា ធម្មា ធម៌ទាំងឡាយជាលោកិយ(១) ធម៌ទាំងឡាយជាលោកុត្តរៈ

១៣) កេនចិ វិញ្ញេយ្យា ធម្មា កេនចិ ន វិញ្ញេយ្យា ធម្មា បិដ្ឋិទុកំ ធម៌ទាំងឡាយដែលគួរដឹងច្បាស់ដោយវិញ្ញាណនីមួយ (មានចក្ខុវិញ្ញាណជាដើម) ធម៌ទាំងឡាយដែលមិនគួរដឹងច្បាស់ដោយវិញ្ញាណនីមួយ ចប់បិដ្ឋិទុកៈតែប៉ុណ្ណោះ ។

១៤) អាសវា ធម្មា នោ អាសវា ធម្មា ធម៌ទាំងឡាយជា

---

១- ប្រែថាប្រព្រឹត្តទៅក្នុងលោក, លោកសព្ទក្នុងទីនេះសំដៅយកវដ្ដៈ ។

អាសវៈ(១) ធម៌ទាំងឡាយមិនមែនជាអាសវៈ

១៥) សាសវា ធម្មា អនាសវា ធម្មា ធម៌ទាំងឡាយប្រព្រឹត្ត ទៅជាមួយនឹងអាសវៈ ធម៌ទាំងឡាយមិនប្រព្រឹត្តទៅជាមួយនឹងអាសវៈ

១៦) អាសវសម្បយុត្តា ធម្មា អាសវវិប្បយុត្តា ធម្មា ធម៌ទាំងឡាយប្រកបដោយអាសវៈ ធម៌ទាំងឡាយប្រាសចាកអាសវៈ

១៧) អាសវា ចេវ ធម្មា សាសវា ច សាសវា ចេវ ធម្មា នោ ច អាសវា ធម៌ទាំងឡាយជាអាសវៈផង ប្រព្រឹត្តទៅជាមួយនឹងអាសវៈផង ធម៌ទាំងឡាយគ្រាន់តែប្រព្រឹត្តទៅជាមួយនឹងអាសវៈ តែមិនមែនជាអាសវៈ

១៨) អាសវា ចេវ ធម្មា អាសវសម្បយុត្តា ច

---

១- អាសវៈសព្ទនេះប្រែថា ហូរទៅគឺហូរទៅតាមបញ្ចទ្វារជាដើមឬហូរតាមផ្លូវធម៌រហូតដល់គោត្រភូ, ហូរតាមឱកាសរហូតដល់ភវគ្គព្រហ្ម មួយទៀត អាសវសព្ទជាឈ្មោះរបស់គ្រឿងស្រវឹងមានទឹកមេរ័យជាដើម មួយទៀត អាសវសព្ទប្រែថា ញុំាងសត្វក្នុងវដ្តទុក្ខឲ្យកើតឡើង មួយទៀត អាសវៈជាឈ្មោះអសុចិ ស្មោកគ្រោកទាំងពួង សវសព្ទប្រែថា ហូរទៅ អសុចិ ហូរទៅជាប្រក្រតី ហៅថា អាសវៈ ។

អាសវសម្បយុត្តា ចេវ ធម្មា នោ ច អាសវា
ធម៌ទាំងឡាយជាអាសវៈផង ប្រកបដោយអាសវៈផង ធម៌ទាំងឡាយគ្រាន់តែប្រកបដោយអាសវៈ តែមិនមែនជាអាសវៈ

១៩) អាសវវិប្បយុត្តា ខោ បន ធម្មា សាសវាបិ អនាសវាបិ អាសវគោច្ឆកំ ធម៌ទាំងឡាយប្រាសចាកអាសវៈ តែប្រព្រឹត្តទៅជាមួយនឹងអាសវៈ ធម៌ទាំងឡាយប្រាសចាកអាសវៈផង មិនប្រព្រឹត្តទៅជាមួយនឹងអាសវៈផង ចប់ពួកអាសវៈតែប៉ុណ្ណេះ ។

២០) សញ្ញោជនា ធម្មា នោ សញ្ញោជនា ធម្មា
ធម៌ទាំងឡាយជាសញ្ញោជនៈ(១) ធម៌ទាំងឡាយមិនមែនជាសញ្ញោជនៈ

២១) សញ្ញោជនិយា ធម្មា អសញ្ញោជនិយា ធម្មា
ធម៌ទាំងឡាយជាប្រយោជន៍ដល់សញ្ញោជនៈ ធម៌ទាំងឡាយមិនមែនជាប្រយោជន៍ដល់សញ្ញោជនៈ

២២) សញ្ញោជនសម្បយុត្តា ធម្មា សញ្ញោជនវិប្បយុត្តា ធម្មា ធម៌ទាំងឡាយប្រកបដោយសញ្ញោជនៈ ធម៌ទាំងឡាយប្រាសចាកសញ្ញោជនៈ

---

១ ធម៌ប្រកបសត្វក្នុងវដ្តៈ ។

២៣) សញ្ញោជនា ចេវ ធម្មា សញ្ញោជនិយា ច សញ្ញោជនិយា ចេវ ធម្មា នោ ច សញ្ញោជនា ធម៌ទាំងឡាយជាសញ្ញោជនៈផង ជាប្រយោជន៍ដល់សញ្ញោជនៈផង ធម៌ទាំងឡាយគ្រាន់តែជាប្រយោជន៍ដល់សញ្ញោជនៈ តែមិនមែនជាសញ្ញោជនៈ

២៤) សញ្ញោជនា ចេវ ធម្មា សញ្ញោជនសម្បយុត្តា ច សញ្ញោជនសម្បយុត្តា ចេវ ធម្មា នោ ច សញ្ញោជនា ធម៌ទាំងឡាយជាសញ្ញោជនៈផងប្រកបដោយសញ្ញោជនៈផង ធម៌ទាំងឡាយគ្រាន់តែប្រកបដោយសញ្ញោជនៈ តែមិនមែនជាសញ្ញោជនៈ

២៥) សញ្ញោជនវិប្បយុត្តា ខោ បន ធម្មា សញ្ញោជនិយាបិ អសញ្ញោជនិយាបិ សញ្ញោជនគោច្ឆកំ ធម៌ទាំងឡាយប្រាសចាកសញ្ញោជនៈ តែជាប្រយោជន៍ដល់សញ្ញោជនៈ ធម៌ទាំងឡាយប្រាសចាកសញ្ញោជនៈផង មិនជាប្រយោជន៍ដល់សញ្ញោជនៈផង ចប់គូសញ្ញោជនៈតែប៉ុណ្ណេះ ។

២៦) គន្ថា ធម្មា នោ គន្ថា ធម្មា ធម៌ទាំងឡាយជាគន្ថៈ(១) ធម៌ទាំងឡាយមិនមែនជាគន្ថៈ

---

១– ធម៌ដោតក្រងសត្វទុកក្នុងវដ្តៈ ដោយអំណាចចុតិ និងបដិសន្ធិ ។

២៧) គន្ថនិយា ធម្មា អគន្ថនិយា ធម្មា ធម៌ទាំងឡាយ

ដែលគន្ថៈគប្បីដោតក្រង ធម៌ទាំងឡាយដែលគន្ថៈមិនគប្បីដោតក្រង

២៨) គន្ថសម្បយុត្តា ធម្មា គន្ថវិប្បយុត្តា ធម្មា

ធម៌ទាំងឡាយប្រកបដោយគន្ថៈ ធម៌ទាំងឡាយប្រាសចាកគន្ថៈ

២៩) គន្ថា ចេវ ធម្មា គន្ថនិយា ច គន្ថនិយា ចេវ

ធម្មា នោ ច គន្ថា ធម៌ទាំងឡាយជាគន្ថៈផង ដែលគន្ថៈគប្បីដោត

ក្រងផង ធម៌ទាំងឡាយដែលគន្ថៈគប្បីដោតក្រង តែមិនមែនជាគន្ថៈ

៣០) គន្ថា ចេវ ធម្មា គន្ថសម្បយុត្តា ច គន្ថសម្បយុត្តា

ចេវ ធម្មា នោ ច គន្ថា ធម៌ទាំងឡាយជាគន្ថៈផង ប្រកបដោយ

គន្ថៈផង ធម៌ទាំងឡាយប្រកបដោយគន្ថៈ តែមិនមែនជាគន្ថៈ

៣១) គន្ថវិប្បយុត្តា ខោ បន ធម្មា គន្ថនិយាបិ អគន្ថ-

និយាបិ គន្ថគោច្ឆកំ ធម៌ទាំងឡាយប្រាសចាកគន្ថៈ តែគន្ថៈគប្បី

ដោតក្រង ធម៌ទាំងឡាយប្រាសចាកគន្ថៈផង ដែលគន្ថៈមិនគប្បីដោត

ក្រងផង ចប់គន្ថគោច្ឆកៈ ។

៣២) ឧបាទានា ធម្មា នោ ឧបាទានា ធម្មា ធម៌ជាប់ទាក់ទង

ជាធម៌ (១) ធម៌ជាប់ទាក់ទងមិនមែនជាធម៌

៣៣) ឧបាទានិយា ធម្មា អនុបាទានិយា ធម្មា

ធម៌ជាប់ទាក់ទងដែលជាធម៌គួរប្រកាន់ខ្ជាប់ ធម៌ជាប់ទាក់ទងដែលជាធម៌

មិនគួរប្រកាន់ខ្ជាប់

៣៤) ឧបាទានសម្បយុត្តា ធម្មា ឧបាទានវិប្បយុត្តា ធម្មា

ធម៌ជាប់ទាក់ទងប្រកបដោយធម៌ ធម៌ជាប់ទាក់ទងប្រាសចាកធម៌

៣៥) ឧបាទានា ចេវ ធម្មា ឧបាទានិយា ច ឧបាទានិយា

ចេវ ធម្មា នោ ច ឧបាទានា ធម៌ជាប់ទាក់ទងជាធម៌ផង ដែល

ជាធម៌គួរប្រកាន់ខ្ជាប់ផង ធម៌ជាប់ទាក់ទងដែលជាធម៌គួរប្រកាន់ខ្ជាប់

តែមិនមែនជាធម៌

៣៦) ឧបាទានា ចេវ ធម្មា ឧបាទានសម្បយុត្តា ច ឧបាទាន-

សម្បយុត្តា ចេវ ធម្មា នោ ច ឧបាទានា ធម៌ជាប់ទាក់ទង

ជាធម៌ផង ប្រកបដោយធម៌ផង ធម៌ជាប់ទាក់ទងប្រកបដោយ

ធម៌ តែមិនមែនជាធម៌

---

១-. ធម៌ញាំងសត្វឲ្យលះបង់មិនបាន ។

៣៧ ឱឃវិប្បយុត្តា ខោ បន ធម្មា ឱឃនិយាបិ អនោឃនិយាបិ ធម៌ទាំងឡាយប្រាសចាកឱឃៈ តែ ជាអារម្មណ៍នៃឱឃៈតាមប្រក្រតីក្តី ធម៌ទាំងឡាយប្រាសចាកឱឃៈផង ដែល មិនមែនជាអារម្មណ៍នៃឱឃៈតាមប្រក្រតីក្តី ហៅថាឱឃវិប្បយុត្តា ។

៣៨) យោគា ធម្មា នោ យោគា ធម្មា ធម៌ទាំងឡាយជាយោគៈ(១) ធម៌ទាំងឡាយមិនមែនជាយោគៈ

៣៩) យោគនិយា ធម្មា អយោគនិយា ធម្មា ធម៌ទាំងឡាយដែលជាអារម្មណ៍នៃយោគៈតាមប្រក្រតីក្តី ធម៌ទាំងឡាយដែលមិនជាអារម្មណ៍នៃយោគៈតាមប្រក្រតីក្តី

៤០) យោគសម្បយុត្តា ធម្មា យោគវិប្បយុត្តា ធម្មា ធម៌ទាំងឡាយប្រកបដោយយោគៈ ធម៌ទាំងឡាយដែលប្រាសចាកយោគៈ

៤១) យោគា ចេវ ធម្មា យោគនិយា ច យោគនិយា ចេវ ធម្មា នោ ច យោគា ធម៌ទាំងឡាយជាយោគៈផង ដែល

---

១- ធម៌ញ៉ាំងសត្វឲ្យជាប់ក្នុងភព ។

យោគៈ តែមិនប្រព្រឹត្តកន្លងផង ធម៌ទាំងឡាយដែលយោគៈគប្បីប្រព្រឹត្តកន្លង តែមិនមែនជាយោគៈ

៤២) យោគា ចេវ ធម្មា យោគសម្បយុត្តា ច យោគសម្បយុត្តា ចេវ ធម្មា នោ ច យោគា ធម៌ទាំងឡាយជាយោគៈផង ប្រកបដោយយោគៈផង ធម៌ទាំងឡាយគ្រាន់តែប្រកបដោយយោគៈ តែមិនមែនជាយោគៈ

៤៣) យោគវិប្បយុត្តា ខោ បន ធម្មា យោគនិយាបិ អយោគនិយាបិ យោគគោច្ឆកំ ធម៌ទាំងឡាយប្រាសចាកយោគៈ តែជាផលយោគៈគប្បីប្រព្រឹត្តកន្លង ធម៌ទាំងឡាយប្រាសចាកយោគៈផង ដែលយោគៈមិនគប្បីប្រព្រឹត្តកន្លងផង ចប់ពួកយោគៈ គុច្ឆកៈ ៦

៤៤) នីវរណា ធម្មា នោ នីវរណា ធម្មា ធម៌ទាំងឡាយជានីវរណៈ(១) ធម៌ទាំងឡាយមិនមែនជានីវរណៈ

៤៥) នីវរណិយា ធម្មា អនីវរណិយា ធម្មា ធម៌ទាំងឡាយជាប្រយោជន៍ដល់នីវរណៈ ធម៌ទាំងឡាយមិនមែនជាប្រយោជន៍ដល់នីវរណៈ

---

១- ធម៌ឃាំង ឬការពារកុសល ។

៤៦) នីវរណសម្បយុត្តា ធម្មា នីវរណវិប្បយុត្តា ធម្មា *ធម៌ទាំងឡាយដែលប្រកបដោយនីវរណៈ ធម៌ទាំងឡាយដែលប្រាសចាកនីវរណៈ*

៤៧) នីវរណា ចេវ ធម្មា នីវរណិយា ច នីវរណិយា ចេវ ធម្មា នោ ច នីវរណា *ធម៌ទាំងឡាយជានីវរណៈផង ជាប្រយោជន៍ដល់នីវរណៈផង ធម៌ទាំងឡាយជាប្រយោជន៍ដល់នីវរណៈ តែមិនមែនជានីវរណៈ*

៤៨) នីវរណា ចេវ ធម្មា នីវរណសម្បយុត្តា ច នីវរណសម្បយុត្តា ចេវ ធម្មា នោ ច នីវរណា *ធម៌ទាំងឡាយជានីវរណៈផង ត្រូវប្រកបដោយនីវរណៈផង ធម៌ទាំងឡាយត្រូវប្រកបដោយនីវរណៈ តែមិនមែនជានីវរណៈ*

៤៩) នីវរណវិប្បយុត្តា ខោ បន ធម្មា នីវរណិយាបិ អនីវរណិយាបិ នីវរណគោច្ឆកំ *ធម៌ទាំងឡាយប្រាសចាកនីវរណៈ តែជាប្រយោជន៍ដល់នីវរណៈ ធម៌ទាំងឡាយប្រាសចាកនីវរណៈផង មិនមែនជាប្រយោជន៍ដល់នីវរណៈផង ចប់គុច្ឆនីវរណៈតែប៉ុណ្ណេះ ។*

៥០) បរាមាសា ធម្មា នោ បរាមាសា ធម្មា ធម៌ទាំងឡាយជាបរាមាសៈ(១) ធម៌ទាំងឡាយមិនមែនជាបរាមាសៈ

៥១) បរាមដ្ឋា ធម្មា អបរាមដ្ឋា ធម្មា ធម៌ទាំងឡាយដែលបរាមាសៈស្ទាបអង្អែល ធម៌ទាំងឡាយដែលបរាមាសៈមិនស្ទាបអង្អែល

៥២) បរាមាសសម្បយុត្តា ធម្មា បរាមាសវិប្បយុត្តា ធម្មា ធម៌ទាំងឡាយដែលប្រកបដោយបរាមាសៈ ធម៌ទាំងឡាយដែលប្រាសចាកបរាមាសៈ

៥៣) បរាមាសា ចេវ ធម្មា បរាមដ្ឋា ច បរាមដ្ឋា ចេវ ធម្មា នោ ច បរាមាសា ធម៌ទាំងឡាយជាបរាមាសៈផង ដែលបរាមាសៈស្ទាបអង្អែលផង ធម៌ទាំងឡាយគ្រាន់តែបរាមាសៈស្ទាបអង្អែល តែមិនមែនជាបរាមាសៈ

៥៤) បរាមាសវិប្បយុត្តា ខោ បន ធម្មា បរាមដ្ឋាបិ អបរាមដ្ឋាបិ បរាមាសគោច្ឆកំ ធម៌ទាំងឡាយប្រាសចាកបរាមាសៈ

---

១– សេចក្ដីប្រកាន់ខុស ។

តែមិនមែនជាអាសវៈស្អាប់អន្លែល ធម៌ទាំងឡាយប្រាសចាកអាសវៈផង ដែលអាសវៈមិនស្អប់អន្លែលផង ធម៌ពួកអាសវៈតែប៉ុណ្ណោះ ។

៥៥) សារម្មណា ធម្មា អនារម្មណា ធម្មា ធម៌ទាំងឡាយប្រព្រឹត្តទៅជាមួយនឹងអារម្មណ៍ ធម៌ទាំងឡាយមិនមានអារម្មណ៍

៥៦) ចិត្តា ធម្មា នោ ចិត្តា ធម្មា ធម៌ទាំងឡាយជាចិត្ត ធម៌ទាំងឡាយមិនមែនជាចិត្ត

៥៧) ចេតសិកា ធម្មា អចេតសិកា ធម្មា ធម៌ទាំងឡាយជាចេតសិក ធម៌ទាំងឡាយមិនមែនជាចេតសិក

៥៨) ចិត្តសម្បយុត្តា ធម្មា ចិត្តវិប្បយុត្តា ធម្មា ធម៌ទាំងឡាយប្រកបដោយចិត្ត ធម៌ទាំងឡាយប្រាសចាកចិត្ត

៥៩) ចិត្តសំសដ្ឋា ធម្មា ចិត្តវិសំសដ្ឋា ធម្មា ធម៌ទាំងឡាយច្រឡូកច្រឡំដោយចិត្ត ធម៌ទាំងឡាយមិនច្រឡូកច្រឡំដោយចិត្ត

៦០) ចិត្តសមុដ្ឋានា ធម្មា នោ ចិត្តសមុដ្ឋានា ធម្មា ធម៌ទាំងឡាយតាំងឡើងដោយចិត្ត ធម៌ទាំងឡាយមិនតាំងឡើងដោយចិត្ត

៦១) ចិត្តសហភុនោ ធម្មា នោ ចិត្តសហភុនោ ធម្មា
ធម៌ទាំងឡាយកើតជាមួយនឹងចិត្ត ធម៌ទាំងឡាយមិនកើតជាមួយនឹងចិត្ត

៦២) ចិត្តានុបរិវត្តិនោ ធម្មា នោ ចិត្តានុបរិវត្តិនោ ធម្មា
ធម៌ទាំងឡាយប្រព្រឹត្តទៅតាមចិត្ត ធម៌ទាំងឡាយមិនប្រព្រឹត្តទៅតាមចិត្ត

៦៣) ចិត្តសំសដ្ឋសមុដ្ឋានា ធម្មា នោ ចិត្តសំសដ្ឋ-
សមុដ្ឋានា ធម្មា ធម៌ទាំងឡាយប្រឡូកប្រឡំតាំងឡើងដោយចិត្ត ធម៌
ទាំងឡាយមិនប្រឡូកប្រឡំ មិនតាំងឡើងដោយចិត្ត

៦៤) ចិត្តសំសដ្ឋសមុដ្ឋានសហភុនោ ធម្មា នោ ចិត្ត-
សំសដ្ឋសមុដ្ឋានសហភុនោ ធម្មា ធម៌ទាំងឡាយប្រឡូកប្រឡំ
តាំងឡើងកើតជាមួយនឹងចិត្ត ធម៌ទាំងឡាយមិនប្រឡូកប្រឡំមិនតាំង
ឡើងមិនកើតជាមួយនឹងចិត្ត

៦៥) ចិត្តសំសដ្ឋសមុដ្ឋានានុបរិវត្តិនោ ធម្មា នោ ចិត្ត-
សំសដ្ឋសមុដ្ឋានានុបរិវត្តិនោ ធម្មា ធម៌ទាំងឡាយប្រឡូកប្រឡំ
តាំងឡើងប្រព្រឹត្តទៅតាមចិត្ត ធម៌ទាំងឡាយមិនប្រឡូកប្រឡំមិនតាំង
ឡើងមិនប្រព្រឹត្តទៅតាមចិត្ត

៦៦) អជ្ឈត្តិកា ធម្មា ពាហិរា ធម្មា ធម៌ទាំងឡាយជាខាងក្នុង ធម៌ទាំងឡាយជាខាងក្រៅ

៦៧) ឧបាទា ធម្មា នោ ឧបាទា ធម្មា ធម៌ទាំងឡាយជាឧបាទា ធម៌ទាំងឡាយមិនមែនជាឧបាទា

៦៨) ឧបាទិន្នា ធម្មា អនុបាទិន្នា ធម្មា មហន្តរទុកំ ធម៌ទាំងឡាយដែលកម្មប្រកបដោយកិលេសមានតណ្ហាជាដើម កាន់យកហើយ ធម៌ទាំងឡាយដែលកម្មប្រកបដោយកិលេសមានតណ្ហាជាដើម មិនកាន់យកហើយ ចប់ក្នុងមហន្តរទុកៈតែប៉ុណ្ណេះ ។

៦៩) ឧបាទានា ធម្មា នោ ឧបាទានា ធម្មា ធម៌ទាំងឡាយជាឧបាទាន(១) ធម៌ទាំងឡាយមិនមែនជាឧបាទាន

៧០) ឧបាទានិយា ធម្មា អនុបាទានិយា ធម្មា ធម៌ទាំងឡាយជាប្រយោជន៍ដល់ឧបាទាន ធម៌ទាំងឡាយមិនមែនជាប្រយោជន៍ដល់ឧបាទាន

៧១) ឧបាទានសម្បយុត្តា ធម្មា ឧបាទានវិប្បយុត្តា ធម្មា ធម៌ទាំងឡាយប្រកបដោយឧបាទាន ធម៌ទាំងឡាយប្រាសចាកឧបាទាន

---

១- សេចក្តីប្រកាន់មាំ ។

៧២) ឧបាទានា ចេវ ធម្មា ឧបាទានិយា ច ឧបាទានិយា ចេវ ធម្មា នោ ច ឧបាទានា ធម៌ទាំងឡាយជាឧបាទានផង ជាប្រយោជន៍ដល់ឧបាទានផង ធម៌ទាំងឡាយគ្រាន់តែជាប្រយោជន៍ដល់ឧបាទាន តែមិនមែនជាឧបាទាន

៧៣) ឧបាទានា ចេវ ធម្មា ឧបាទានសម្បយុត្តា ច ឧបាទានសម្បយុត្តា ចេវ ធម្មា នោ ច ឧបាទានា ធម៌ទាំងឡាយជាឧបាទានផង ប្រកបដោយឧបាទានផង ធម៌ទាំងឡាយគ្រាន់តែប្រកបដោយឧបាទាន តែមិនមែនជាឧបាទាន

៧៤) ឧបាទានវិប្បយុត្តា ខោ បន ធម្មា ឧបាទានិយាបិ អនុបាទានិយាបិ ឧបាទានគោច្ឆកំ ធម៌ទាំងឡាយប្រាសចាកឧបាទានតែជាប្រយោជន៍ដល់ឧបាទាន ធម៌ទាំងឡាយប្រាសចាកឧបាទានផង មិនមែនជាប្រយោជន៍ដល់ឧបាទានផង ចប់ពួកឧបាទានតែប៉ុណ្ណេះ ។

៧៥) កិលេសា ធម្មា នោ កិលេសា ធម្មា ធម៌ទាំងឡាយជាកិលេស(១) ធម៌ទាំងឡាយមិនមែនជាកិលេស

---

១– គឺសៅហ្មង ។

៧៦) សង្កិលេសិកា ធម្មា អសង្កិលេសិកា ធម្មា ធម៌ទាំងឡាយគួរដល់នូវសេចក្តីសៅហ្មង ធម៌ទាំងឡាយមិនគួរដល់នូវសេចក្តីសៅហ្មង

៧៧) សង្កិលិដ្ឋា ធម្មា អសង្កិលិដ្ឋា ធម្មា ធម៌ទាំងឡាយដែលសៅហ្មងហើយ ធម៌ទាំងឡាយដែលមិនសៅហ្មងហើយ

៧៨) កិលេសសម្បយុត្តា ធម្មា កិលេសវិប្បយុត្តា ធម្មា ធម៌ទាំងឡាយប្រកបដោយកិលេស ធម៌ទាំងឡាយប្រាសចាកកិលេស

៧៩) កិលេសា ចេវ សង្កិលេសិកា ច សង្កិលេសិកា ចេវ ធម្មា នោ ច កិលេសា ធម៌ទាំងឡាយជាកិលេសផង គួរដល់នូវសេចក្តីសៅហ្មងផង ធម៌ទាំងឡាយគ្រាន់តែគួរដល់នូវសេចក្តីសៅហ្មង តែមិនមែនជាកិលេស

៨០) កិលេសា ចេវ ធម្មា សង្កិលិដ្ឋា ច សង្កិលិដ្ឋា ចេវ ធម្មា នោ ច កិលេសា ធម៌ទាំងឡាយជាកិលេសផង សៅហ្មងហើយផង ធម៌ទាំងឡាយគ្រាន់តែសៅហ្មងហើយ តែមិនមែនជាកិលេស

៨១) កិលេសា ចេវ ធម្មា កិលេសសម្បយុត្តា ច កិលេសសម្បយុត្តា ចេវ ធម្មា នោ ច កិលេសា *ធម៌ទាំងឡាយជាកិលេសផង ប្រកបដោយកិលេសផង ធម៌ទាំងឡាយគ្រាន់តែប្រកបដោយកិលេស តែមិនមែនជាកិលេស*

៨២) កិលេសវិប្បយុត្តា ខោ បន ធម្មា សង្កិលេសិកាបិ អសង្កិលេសិកាបិ កិលេសគោច្ឆកំ *ធម៌ទាំងឡាយប្រាសចាកកិលេស តែគួរដល់នូវសេចក្ដីសៅហ្មង ធម៌ទាំងឡាយប្រាសចាកកិលេសផង មិនគួរដល់នូវសេចក្ដីសៅហ្មងផង ចប់គុច្ឆកកិលេសតែប៉ុណ្ណេះ ។*

៨៣) ទស្សនេន បហាតព្វា ធម្មា ន ទស្សនេន បហាតព្វា ធម្មា *ធម៌ទាំងឡាយគួរលះដោយទស្សនៈ (១) ធម៌ទាំងឡាយមិនគួរលះដោយទស្សនៈ*

៨៤) ភាវនាយ បហាតព្វា ធម្មា ន ភាវនាយ បហាតព្វា ធម្មា *ធម៌ទាំងឡាយដែលគួរលះដោយភាវនា (២) ធម៌ទាំងឡាយដែលមិនគួរលះដោយភាវនា*

---

១- ឃ. ឃើញគឺសំដៅយកសោតាបត្តិមគ្គ ។ ២- មគ្គ ៣ ខាងលើ ។

៨៥) ទស្សនេន បហាតព្វហេតុកា ធម្មា ន ទស្សនេន បហាតព្វហេតុកា ធម្មា ធម៌ទាំងឡាយមានហេតុដែលត្រូវលះដោយទស្សនៈ ធម៌ទាំងឡាយមិនមានហេតុដែលត្រូវលះដោយទស្សនៈ

៨៦) ភាវនាយ បហាតព្វហេតុកា ធម្មា ន ភាវនាយ បហាតព្វហេតុកា ធម្មា ធម៌ទាំងឡាយមានហេតុដែលត្រូវលះដោយភាវនា ធម៌ទាំងឡាយមិនមានហេតុដែលត្រូវលះដោយភាវនា

៨៧) សវិតក្កា ធម្មា អវិតក្កា ធម្មា ធម៌ទាំងឡាយប្រកបដោយវិតក្កៈ(១) ធម៌ទាំងឡាយមិនមានវិតក្កៈ

៨៨) សវិចារា ធម្មា អវិចារា ធម្មា ធម៌ទាំងឡាយប្រព្រឹត្តទៅជាមួយនឹងវិចារៈ(២) ធម៌ទាំងឡាយមិនមានវិចារៈ

៨៩) សប្បីតិកា ធម្មា អប្បីតិកា ធម្មា ធម៌ទាំងឡាយប្រព្រឹត្តទៅជាមួយនឹងបីតិ(៣) ធម៌ទាំងឡាយមិនមានបីតិ

៩០) បីតិសហគតា ធម្មា ន បីតិសហគតា ធម្មា ធម៌ទាំងឡាយប្រកបដោយបីតិ ធម៌ទាំងឡាយមិនប្រកបដោយបីតិ

---

១- ការត្រិះរិះ ។ ២ ការពិចារណា ។ ៣- ការត្រេកអរ ។

៩១) សុខសហគតា ធម្មា ន សុខសហគតា ធម្មា
ធម៌តាំងឡើងប្រកបដោយសុខ ធម៌តាំងឡើងមិនប្រកបដោយសុខ

៩២) ឧបេក្ខាសហគតា ធម្មា ន ឧបេក្ខាសហគតា ធម្មា
ធម៌តាំងឡើងប្រកបដោយឧបេក្ខា ធម៌តាំងឡើងមិនប្រកបដោយឧបេក្ខា

៩៣) កាមាវចរា ធម្មា ន កាមាវចរា ធម្មា ធម៌តាំងឡើង
ជាកាមាវចរ(១) ធម៌តាំងឡើងមិនមែនជាកាមាវចរ

៩៤) រូបាវចរា ធម្មា ន រូបាវចរា ធម្មា ធម៌តាំងឡើង
ជារូបាវចរ ធម៌តាំងឡើងមិនមែនជារូបាវចរ

៩៥) អរូបាវចរា ធម្មា ន អរូបាវចរា ធម្មា ធម៌តាំងឡើង
ជាអរូបាវចរ ធម៌តាំងឡើងមិនមែនជាអរូបាវចរ

៩៦) បរិយាបន្នា ធម្មា អបរិយាបន្នា ធម្មា ធម៌តាំងឡើង
ជាបរិយាបន្នៈ(២) ធម៌តាំងឡើងជាអបរិយាបន្នៈ

៩៧) និយ្យានិកា ធម្មា អនិយ្យានិកា ធម្មា ធម៌តាំងឡើង
ជានិយ្យានិកៈ(៣) ធម៌តាំងឡើងមិនមែនជានិយ្យានិកៈ

---

១– ប្រព្រឹត្តទៅក្នុងកាម ។ ២– រាប់បញ្ចូលក្នុងតេភូមិកវដ្ដៈ ។ ៣– ធម៌កាត់នូវវដ្ដមូល ធ្វើព្រះនិព្វានឲ្យជាអារម្មណ៍ហើយចេញចាកវដ្ដៈ ។

៩៨) និយតា ធម្មា អនិយតា ធម្មា ធម៌ទាំងឡាយទៀង
ធម៌ទាំងឡាយមិនទៀង

៩៩) សឧត្តរា ធម្មា អនុត្តរា ធម្មា ធម៌ទាំងឡាយប្រព្រឹត្តទៅ
ជាមួយនឹងឧត្តរៈ(១) ធម៌ទាំងឡាយមិនមានឧត្តរៈ

១០០) សរណា ធម្មា អរណា ធម្មា បិដ្ឋិទុកំ ធម៌
ទាំងឡាយប្រព្រឹត្តទៅព្រមដោយរណៈ(២) ធម៌ទាំងឡាយមិនមានរណៈ
ចប់បិដ្ឋិទុកៈតែប៉ុណ្ណោះ ។

ចប់ អភិធម្មមាតិកា

---

## សុត្តន្តមាតិកា

១) វិជ្ជាភាគិនោ ធម្មា អវិជ្ជាភាគិនោ ធម្មា ធម៌ទាំងឡាយ
ប្រព្រឹត្តទៅក្នុងចំណែកនៃវិជ្ជា ធម៌ទាំងឡាយប្រព្រឹត្តទៅក្នុងចំណែកនៃ
អវិជ្ជា

---

១- ការបៀតបៀន ។ ២- កិលេស ចុះក្រោម ។

២) វិជ្ជូបមា ធម្មា វជិរូបមា ធម្មា ធម៌ទាំងឡាយប្រៀបដូចជាផ្លេកបន្ទោរ(១) ធម៌ទាំងឡាយប្រៀបដូចជាពេជ្រ(២)

៣) ពាលា ធម្មា បណ្ឌិតា ធម្មា ធម៌ទាំងឡាយដែលបំពាក់ទៅក្នុងបុគ្គលពាល(៣) ធម៌ទាំងឡាយដែលបំពាក់ទៅក្នុងបុគ្គលជាបណ្ឌិត(៤)

៤) កណ្ហា ធម្មា សុក្កា ធម្មា ធម៌ទាំងឡាយមានសភាពខ្មៅ(៥) ធម៌ទាំងឡាយមានសភាពស(៦)

៥) តបនិយា ធម្មា អតបនិយា ធម្មា ធម៌ទាំងឡាយដែលគួរដល់ការក្ដៅក្រហាយ(៧) ធម៌ទាំងឡាយមិនគួរដល់ការក្ដៅក្រហាយ

៦) អធិវចនា ធម្មា អធិវចនបថា ធម្មា ធម៌ទាំងឡាយគ្រាន់តែជាឈ្មោះ ធម៌ទាំងឡាយគ្រាន់តែជាផ្លូវនៃឈ្មោះ

---

១- ធម៌ដែលមានពន្លឺនូវស្រស់ស្រាយ តែមិនអាចដកនូវគំនិតកិលេសបាន ។ ២- ធម៌ដែលមានពន្លឺនូវសេចក្ដីក្លាហាន បន្ទឹកកាត់នូវគំនិតកិលេសបាន ។ ៣ ធម៌ទាំងនៅក្នុងមនុស្សពាល ឬធ្វើមនុស្សឲ្យទៅជាពាលវិញ ។ ៤- ធម៌ទាំងនៅក្នុងបណ្ឌិត ឬធ្វើមនុស្សឲ្យទៅជាបណ្ឌិតវិញ ។ ៥- ធម៌ធ្វើចិត្តឲ្យសៅហ្មងខ្មៅ ។ ៦ ធម៌ធ្វើចិត្តឲ្យបានបរិសុទ្ធ ។ ៧- ធម៌ដុតកំដៅក្នុងលោកនេះនិងលោកខាងមុខ ។

៧) និវត្តិ ធម្មា និវត្តិបហា ធម្មា ធម៌ទាំងឡាយជានិវត្តិ[១] ធម៌ទាំងឡាយជាគន្ធនៃនិវត្តិ

៨) បញ្ញត្តិ ធម្មា បញ្ញត្តិបហា ធម្មា ធម៌ទាំងឡាយជាបញ្ញត្តិ ធម៌ទាំងឡាយជាគន្ធនៃបញ្ញត្តិ

៩) នាមញ្ច រូបញ្ច នាម[២] និងរូប[៣]

១០) អវិជ្ជា ច ភវតណ្ហា ច អវិជ្ជា[៤] និងភវតណ្ហា[៥]

១១) ភវទិដ្ឋិ ច វិភវទិដ្ឋិ ច ភវទិដ្ឋិ[៦] និងវិភវទិដ្ឋិ[៧]

១២) សស្សតទិដ្ឋិ ច ឧច្ឆេទទិដ្ឋិ ច សស្សតទិដ្ឋិ[៨] និងឧច្ឆេទទិដ្ឋិ[៩]

---

១– ប្រែថា ពោលដោយមិនសល់សំដៅយកពាក្យវិគ្គហៈ ឬ វិគ្រោះ អធិប្បាយគ្រាប់ហេតុគ្រាប់ផល ដូចពាក្យថា សភាវៈឯណាតាក់តែងសត្វ សភាវៈនោះហៅថាសង្ខារជាដើម ។ ២– ប្រែថាឈ្មោះ, ប្រែថាទន់ទៅ, ឬ បង្អោនទៅ ។ ៣– ប្រែថាវិនាសទៅ, លំបាក ។ ៤– មិនដឹងនូវអរិយសច្ចតាំង៤ ។ ៥– សេចក្តីប្រាថ្នាក្នុងភព ។ ៦– សេចក្តីយល់ឃើញថាសត្វកើតទៀត ។ ៧– សេចក្តីយល់ឃើញថាសត្វមិនកើតទៀត ។ ៨– សេចក្តីយល់ឃើញថាខ្លួននិងលោកជាសភាវៈទៀង ។ ៩– សេចក្តីយល់ឃើញថាសត្វសូន្យមិនកើតទៀត ។

១៣) អន្តវាទិដ្ឋិ ច អនន្តវាទិដ្ឋិ ច *អន្តវាទិដ្ឋិ(១) និង អនន្តវាទិដ្ឋិ(២)*

១៤) បុព្វន្តានុទិដ្ឋិ ច អបរន្តានុទិដ្ឋិ ច *បុព្វន្តានុទិដ្ឋិ(៣) និងអបរន្តានុទិដ្ឋិ(៤)*

១៥) អហិរិកញ្ច អនោត្តប្បញ្ច *សេចក្ដីមិនខ្មាស់បាប និងសេចក្ដីមិនខ្លាចចំពោះបាប*

១៦) ហិរិ ច ឱត្តប្បញ្ច *សេចក្ដីខ្មាស់បាប និងសេចក្ដីខ្លាចនឹងបាប*

១៧) ទោវចស្សតា ច បាបមិត្តតា ច *ភាពជាបុគ្គលប្រដៅក្រ និងភាពជាបុគ្គលមានមិត្រអាក្រក់*

១៨) សោវចស្សតា ច កល្យាណមិត្តតា ច *ភាពជាបុគ្គលប្រដៅងាយ និងភាពជាបុគ្គលមានមិត្រល្អ*

១៩) អាបត្តិកុសលតា ច អាបត្តិវុដ្ឋានកុសលតា ច *សេចក្ដីឈ្លាសវៃក្នុងអាបត្តិ និងសេចក្ដីឈ្លាសវៃក្នុងការចេញចាកអាបត្តិ*

---

*១- សេចក្ដីយល់ឃើញថា លោកមានទីបំផុត ។ ២- សេចក្ដីយល់ឃើញថា លោកមិនមានទីបំផុត ។ ៣- សេចក្ដីយល់ឃើញតាមចំណែកនៃខន្ធខាងដើម ។ ៤- សេចក្ដីយល់ឃើញតាមចំណែកនៃខន្ធខាងចុង ។*

២០) សមាបត្តិកុសលតា ប សមាបត្តិវុដ្ឋានកុសលតា ប សេចក្តីឈ្លាសវៃក្នុងសមាបត្តិ និងសេចក្តីឈ្លាសវៃក្នុងការចេញចាកសមាបត្តិ

២១) ធាតុកុសលតា ប មនសិការកុសលតា ប សេចក្តីឈ្លាសវៃក្នុងធាតុ និងសេចក្តីឈ្លាសវៃក្នុងការធ្វើទុកក្នុងចិត្ត

២២) អាយតនកុសលតា ប បដិច្ចសមុប្បាទកុសលតា ប សេចក្តីឈ្លាសវៃក្នុងអាយតនៈ និងសេចក្តីឈ្លាសវៃក្នុងបដិច្ចសមុប្បាទ

២៣) ឋានកុសលតា ប អដ្ឋានកុសលតា ប សេចក្តីឈ្លាសវៃក្នុងហេតុ និងសេចក្តីឈ្លាសវៃក្នុងការមិនមែនជាហេតុ

២៤) អាជ្ជវោ ប មទ្ទវោ ប សេចក្តីត្រង់ និងសេចក្តីទន់ភ្លន់

២៥) ខន្តិ ប សោរច្ចំ សេចក្តីអត់ធន់ និងសេចក្តីស្ងប់ស្ងៀម

២៦) សាខល្យញ្ច បដិសន្ថារោ ប សេចក្តីស្រស់ស្រាយ និងការស្រះស្រលទទួល

២៧) ឥន្ទ្រិយេសុ អគុត្តទ្វារតា ប ភោជនេ អមត្តញ្ញុតា ប

ការមិនគ្រប់គ្រងទ្វារឥន្ទ្រិយ និងសេចក្តីមិនដឹងប្រមាណក្នុងភោជន

២៨) ឥន្ទ្រិយេសុ គុត្តទ្វារតា ច (ភោជនេ មត្តញ្ញុតា ច ការគ្រប់គ្រងទ្វារក្នុងឥន្ទ្រិយ ទំនងសេចក្ដីដឹងប្រមាណក្នុងភោជន

២៩) មុដ្ឋស្សច្ចញ្ច អសម្បជញ្ញញ្ច សេចក្ដីភ្លេចស្មារតី ទំនងសេចក្ដីមិនដឹងខ្លួន

៣០) សតិ ច សម្បជញ្ញញ្ច ស្មារតី ទំនងសេចក្ដីដឹងខ្លួន

៣១) បដិសង្ខានពលញ្ច ភាវនាពលញ្ច កម្លាំងនៃការពិចារណា ទំនងកម្លាំងនៃភាវនា

៣២) សមថោ ច វិបស្សនា ច សមថៈ(1) ទំនងវិបស្សនា(2)

៣៣) សមថនិមិត្តញ្ច បគ្គាហនិមិត្តញ្ច និមិត្តរបស់សមថៈ ទំនងនិមិត្តនៃការព្យាយាមផ្គងឡើង

៣៤) បគ្គាហោ ច អវិក្ខេបោ ច សេចក្ដីព្យាយាម ទំនងសេចក្ដីមិនរាយមាយ

៣៥) សីលវិបត្តិ ច ទិដ្ឋិវិបត្តិ ច ការវិបត្តិនៃសីល ទំនងការវិបត្តិនៃទិដ្ឋិ

---

១ សភាវៈទ្រាប់នូវធម៌ជាសត្រូវ ។ ២ ធម្មជាតិឃើញដោយអាការផ្សេងៗ ។

៣៦) សីលសម្បទា ប ទិដ្ឋិសម្បទា ប *ការបរិបូណ៌នៃសីល និងការបរិបូណ៌នៃទិដ្ឋិ*

៣៧) សីលវិសុទ្ធិ ប ទិដ្ឋិវិសុទ្ធិ ប *សេចក្ដីបរិសុទ្ធនៃសីល និងសេចក្ដីបរិសុទ្ធនៃទិដ្ឋិ*

៣៨) ទិដ្ឋិវិសុទ្ធិ ខោ បន យថាទិដ្ឋិស្ស ប បធានំ *សេចក្ដីបរិសុទ្ធនៃទិដ្ឋិ និងសេចក្ដីព្យាយាមរបស់បុគ្គលដែលមានទិដ្ឋិដ៏សមគួរ*

៣៩) សំវេគោ ប សំវេជនិយេសុ ឋានេសុ សំវិគ្គស្ស ប យោនិសោ បធានំ *សេចក្ដីសង្វេគក្នុងទីដែលគួរសង្វេគទាំងឡាយ និងសេចក្ដីព្យាយាមដោយឧបាយនៃបុគ្គល ដែលបានសេចក្ដីសង្វេគ*

៤០) អសន្តុដ្ឋិតា ប កុសលេសុ ធម្មេសុ អប្បដិវានិតា ប បធានស្មឹ *សេចក្ដីមិនសន្ដោសក្នុងកុសលធម៌ទាំងឡាយ និងសេចក្ដីមិនបង្វែរថយក្នុងព្យាយាម*

៤១) វិជ្ជា ប វិមុត្តិ ប *វិជ្ជា និងវិមុត្តិ*

៤២) ខយេ ញាណំ អនុប្បាទេ ញាណន្តិ *សេចក្ដីដឹងក្នុងធម៌* ១)

ជាគ្រឿងគាស់ទៅនៃកិលេស នឹងសេចក្តីដឹកក្នុងធម៌(១) ដែលធ្វើកិលេសមិនឲ្យកើតឡើងទៀត ។

## សុត្តន្តមាតិកា ទ្វាចត្តាឡីសទុកំ សមត្តំ

សុត្តន្តមាតិកា មានទុកៈ ៤២ ចប់តែប៉ុណ្ណោះ ។

---

១- អរិយផល ។

# ខន្ធវិភង្គ

## ក្នជបាលី

(តទនន្តរំ[១] វិភង្គប្បករណំ នាមេតំ *លំដាប់អំពីបករណៈឈ្មោះធម្មសង្គណីនោះមក យើងនឹងសូត្រនូវបករណៈឈ្មោះវិភង្គ ឯបករណៈឈ្មោះវិភង្គនោះគឺ* )

បញ្ចក្ខន្ធា រូបក្ខន្ធោ វេទនាខន្ធោ សញ្ញាខន្ធោ សង្ខារក្ខន្ធោ វិញ្ញាណក្ខន្ធោ *ខន្ធទាំងឡាយ ៥ គឺ រូបខន្ធ ១ វេទនាខន្ធ ១ សញ្ញាខន្ធ ១ សង្ខារខន្ធ ១ វិញ្ញាណខន្ធ ១ ។*

តត្ថ កតមោ រូបក្ខន្ធោ *បណ្ដាខន្ធទាំងនោះ រូបខន្ធតើដូចម្ដេច ។*

យំ កិញ្ចិ រូបំ អតីតានាគតប្បច្ចុប្បន្នំ អជ្ឈត្តំ វា ពហិទ្ធា វា ឱឡារិកំ វា សុខុមំ វា ហីនំ វា បណីតំ វា យំ ទូរេ

---

(១) ត្រង់សេក្រៅពាក្យខាងដើម គ្រប់គម្ពីរទាំង ៦ មេ មិនមានក្នុងបាលីអភិធម្មបិដកទេ តែលោកអ្នកប្រាជ្ញជាន់ដើម បានរៀបរៀងក្នុងកាលក្រោយ ដើម្បីជាក់ខាងដើមនេះ ដើម្បីឲ្យងាយនឹងឈ្មោះធម៌មួយសង្កាត់ៗ ប៉ុណ្ណោះ ។

សន្តិកេ វា *រូបឯណានីមួយ ជាអតីតក្តី ជាអនាគតក្តី ជាបច្ចុប្បន្នក្តី ខាងក្នុងក្តី ខាងក្រៅក្តី គ្រោតគ្រាតក្តី ល្អិតក្តី ថោកទាបក្តី ឧត្តមក្តី ក្នុងទីឆ្ងាយក្តី ក្នុងទីជិតក្តី*

តទេកជ្ឈំ អភិសញ្ញូហិត្វា អភិសង្ខិបិត្វា អយំ វុច្ចតិ រូបក្ខន្ធោ *ទាំងនេះលោកបានប្រមូលរួម ឲ្យរូបទាំងអស់នោះ ជាមួយគ្នា ហៅថា រូបក្ខន្ធ ។*

តត្ថ កតមោ វេទនាក្ខន្ធោ *បណ្តាខន្ធទាំងនោះ វេទនាខន្ធតើ ដូចម្តេច ? ។*

យា កាចិ វេទនា អតីតានាគតបច្ចុប្បន្នា អជ្ឈត្តា វា ពហិទ្ធា វា ឱឡារិកា វា សុខុមា វា ហីនា វា បណីតា វា យា ទូរេ សន្តិកេ វា *វេទនាឯណានីមួយ ជាអតីតក្តី ជាអនាគតក្តី ជាបច្ចុប្បន្នក្តី ខាងក្នុងក្តី ខាងក្រៅក្តី គ្រោតគ្រាតក្តី ល្អិតក្តី ថោកទាបក្តី ឧត្តមក្តី ក្នុងទីឆ្ងាយក្តី ក្នុងទីជិតក្តី*

តទេកជ្ឈំ អភិសញ្ញូហិត្វា អភិសង្ខិបិត្វា អយំ វុច្ចតិ វេទនាក្ខន្ធោ *ទាំងនេះលោកបានប្រមូលរួម ឲ្យវេទនាទាំងអស់នោះ ជាមួយគ្នា ហៅថា វេទនាខន្ធ*

តត្ថ កតមោ សញ្ញាខន្ធោ បណ្ដាខន្ធទាំងនោះ សញ្ញាខន្ធ តើដូចម្ដេច ។

យា កាចិ សញ្ញា អតីតានាគតប្បច្ចុប្បន្នា អជ្ឈត្តា វា ពហិទ្ធា វា ឱឡារិកា វា សុខុមា វា ហីនា វា បណីតា វា យា ទូរេ សន្តិកេ វា សញ្ញាឯណានីមួយ ជាអតីតក្ដី ជាអនាគតក្ដី ជាបច្ចុប្បន្នក្ដី ខាងក្នុងក្ដី ខាងក្រៅក្ដី គ្រោតគ្រាតក្ដី ល្អិតក្ដី ថោកទាបក្ដី ឧត្ដមក្ដី ក្នុងទីឆ្ងាយក្ដី ក្នុងទីជិតក្ដី

តទេកជ្ឈំ អភិសញ្ញូហិត្វា អភិសង្ខិបិត្វា អយំ វុច្ចតិ សញ្ញាខន្ធោ ខន្ធនេះលោកបានប្រមូលរួបរួម នូវសញ្ញាទាំងអស់នោះ ជាមួយគ្នា ហៅថា សញ្ញាខន្ធ ។

តត្ថ កតមោ សង្ខារក្ខន្ធោ បណ្ដាខន្ធទាំងនោះ សង្ខារក្ខន្ធ តើដូចម្ដេច ។

យេ កេចិ សង្ខារា អតីតានាគតប្បច្ចុប្បន្នា អជ្ឈត្តា វា ពហិទ្ធា វា ឱឡារិកា វា សុខុមា ហីនា វា បណីតា វា យេ ទូរេ សន្តិកេ វា សង្ខារទាំងឡាយឯណានីមួយ ជាអតីតក្ដី ជាអនាគតក្ដី ជាបច្ចុប្បន្នក្ដី ខាងក្នុងក្ដី ខាងក្រៅក្ដី គ្រោតគ្រាតក្ដី ល្អិតក្ដី ថោកទាបក្ដី ឧត្ដមក្ដី ក្នុងទីឆ្ងាយក្ដី ក្នុងទីជិតក្ដី ។

តទេកជ្ឈំ អភិសញ្ញូហិត្វា អភិសង្ខិបិត្វា អយំ វុច្ចតិ សង្ខារក្ខន្ធោ ខន្ធនេះលោកបានប្រមូលរួបរួម នូវសង្ខារទាំងអស់នោះ ជាមួយគ្នា ហៅថា សង្ខារក្ខន្ធ ។

តត្ថ កតមោ វិញ្ញាណក្ខន្ធោ បណ្ដាខន្ធទាំងនោះ វិញ្ញាណក្ខន្ធ តើដូចម្ដេច ? ។

យំ កិញ្ចិ វិញ្ញាណំ អតីតានាគតប្បច្ចុប្បន្នំ អជ្ឈត្តំ វា ពហិទ្ធា វា ឱឡារិកំ វា សុខុមំ វា ហីនំ វា បណីតំ វា យំ ទូរេ សន្តិកេ វា វិញ្ញាណឯណានីមួយ ជាអតីតក្ដី ជាអនាគតក្ដី ជាបច្ចុប្បន្នក្ដី ខាងក្នុងក្ដី ខាងក្រៅក្ដី គ្រោតគ្រាតក្ដី ល្អិតក្ដី ថោកទាបក្ដី ឧក្កដ្ឋក្ដី ក្នុងទីឆ្ងាយក្ដី ក្នុងទីជិតក្ដី

តទេកជ្ឈំ អភិសញ្ញូហិត្វា អភិសង្ខិបិត្វា អយំ វុច្ចតិ វិញ្ញាណក្ខន្ធោ ខន្ធនេះលោកបានប្រមូលរួបរួម នូវវិញ្ញាណទាំងអស់នោះ ជាមួយគ្នា ហៅថា វិញ្ញាណក្ខន្ធ ។

(អយំ ខន្ធវិភង្គាទិ អដ្ឋារសវិធេន វិភត្តំ វិភង្គប្បករណំ នាម សមត្តំ នេះឈ្មោះថាវិភង្គ មានខន្ធវិភង្គជាដើម; បករណៈឈ្មោះ វិភង្គដែលលោកចែកហើយដោយចំណែក ១៨ ប្រការ ចប់តែប៉ុណ្ណេះ ។

# ធាតុកថា

## ក្នុងបាលី

### មាតិកា(១)

(តទនន្តរំ ធាតុកថាបករណំ នាមេតំ *ល់ដាច់អំពីបករណៈឈ្មោះវិភង្គនោះមក យើងនឹងសូត្រនូវបករណៈឈ្មោះធាតុកថា ឯបករណៈឈ្មោះធាតុកថានោះគឺ)*

---

(១) មាតិកាមាន៥ពួក. ក) នយមាតិកា មាតិកានៃន័យ ដែលលោកដាក់ទុកដោយបទ ១៤ គឺ សង្គហោ អសង្គហោ ។ល។ វិប្បយុត្តេន សង្គហិតំ អសង្គហិតំ ។ ខ) អព្ភន្តរមាតិកា មាតិកាខាងក្នុង ដែលលោកដាក់ទុកដោយបទ ១២៥ គឺៈ បញ្ចក្ខន្ធា ។ល។ មនសិការោ ។ គ) នយមុខមាតិកា មាតិកាជាប្រធាននៃន័យ ដែលលោកដាក់ទុកដោយបទ ៤ គឺ តីហិ សង្គហោ តីហិ អសង្គហោ ចតូហិ សម្បយោគោ ចតូហិ វិប្បយោគោ ។ ឃ) លក្ខណមាតិកា មាតិកាដែលសំដែងនូវលក្ខណៈដែលលោកដាក់ទុកដោយបទ ២ គឺ សភាគោ វិសភាគោ។ ង) ពាហិរមាតិកា មាតិកាខាងក្រៅ ដែលលោកបំព្រួញនូវតិកបទ ៦៦ និងទុកបទ ២០០ ។ ២) សង្គ្រោះមាន ៤ ក) ជាតិសង្គហៈ សង្គ្រោះដោយជាតិ ដូចយ៉ាងជាតិក្សត្រ, ជាតិព្រាហ្មណ៍, ជាតិអ្នកជំនួញប្រែ, ជាតិអ្នកគ្រួ, ឬក៏ធម៌ ៣ យ៉ាងនេះគឺៈ សម្មាវាចា, សម្មាកម្មន្តោ សម្មាអាជីវោ សង្គ្រោះចូលក្នុងសីលក្ខន្ធ ។ ខ) សញ្ជាតិសង្គហៈ សង្គ្រោះរួមជាតិ ដូចជាតិអ្នកដែនកោសល ជាតិអ្នកដែនមគធៈ ឬក៏ធម៌៣យ៉ាងនេះគឺៈ សម្មាវាយាមោ, សម្មាសតិ សម្មាសមាធិ សង្គ្រោះចូលក្នុងសមាធិក្ខន្ធ ។ គ) កិរិយាសង្គហៈ សង្គ្រោះតាមអំពើដែលធ្វើរួមមកហើយ ដូចយ៉ាងអ្នកជិះដំរី អ្នកជិះសេះ អ្នកជិះរថ ឬក៏ធម៌២យ៉ាងគឺ សម្មាទិដ្ឋិ សម្មាសង្កប្បោ សង្គ្រោះចូលក្នុងបញ្ញាខន្ធ ។ ឃ) គណនសង្គហៈ សង្គ្រោះដោយការរាប់ដូចយ៉ាងចក្ខាយតនៈ រាប់ជារូបក្ខន្ធជាដើម ។

សង្គហោ អសង្គហោ ការសង្គ្រោះ ការមិនសង្គ្រោះ

សង្គហិតេន អសង្គហិតំ កិរិយាមិនសង្គ្រោះ មួយអន្លើ ដោយកិរិយាសង្គ្រោះ

អសង្គហិតេន សង្គហិតំ កិរិយាសង្គ្រោះ មួយអន្លើ ដោយកិរិយាមិនសង្គ្រោះ

សង្គហិតេន សង្គហិតំ កិរិយាសង្គ្រោះ មួយអន្លើ ដោយកិរិយាសង្គ្រោះ

អសង្គហិតេន អសង្គហិតំ កិរិយាមិនសង្គ្រោះ មួយអន្លើ ដោយកិរិយាមិនសង្គ្រោះ

សម្បយោគោ វិប្បយោគោ ការប្រកបព្រម ការប្រាសចេញ

សម្បយុត្តេន វិប្បយុត្តំ ការប្រាសចេញ មួយអន្លើដោយ ការប្រកបព្រម

វិប្បយុត្តេន សម្បយុត្តំ ការប្រកបព្រម មួយអន្លើដោយ ការប្រាសចេញ

សម្បយុត្តេន សម្បយុត្តំ ការប្រកបព្រម មួយអន្លើដោយ

វិប្បយុត្តេន វិប្បយុត្តំ ការប្រាសចេញ មួយអន្លើដោយការប្រាសចេញ

សង្គហិតេន ត:ម្បយុត្តំ វិប្បយុត្តំ ការប្រកបព្រមនឹងការប្រាសចេញ មួយអន្លើដោយកិរិយាសង្គ្រោះ

សម្បយុត្តេន សង្គហិតំ អសង្គហិតំ កិរិយាសង្គ្រោះនឹងកិរិយាមិនសង្គ្រោះ មួយអន្លើដោយការប្រកបព្រម

អសង្គហិតេន សម្បយុត្តំ វិប្បយុត្តំ ការប្រកបព្រមនឹងការប្រាសចេញ មួយអន្លើដោយកិរិយាមិនសង្គ្រោះ

វិប្បយុត្តេន សង្គហិតំ អសង្គហិតន្តិ[1] កិរិយាសង្គ្រោះនឹងកិរិយាមិនសង្គ្រោះ មួយអន្លើដោយការប្រាសចេញ ។

បញ្ចក្ខន្ធា ទ្វាទសាយតនានិ អដ្ឋារស ធាតុយោ ចត្តារិ សច្ចានិ ពាវីសតិន្ទ្រិយានិ បដិច្ចសមុប្បាទោ ចត្តារោ សតិប្បដ្ឋានា ចត្តារោ សម្មប្បធានា ចត្តារោ ឥទ្ធិបាទា ចត្តារិ ឈានានិ ចតស្សោ អប្បមញ្ញាយោ បញ្ចិន្ទ្រិយានិ បញ្ចពលានិ សត្ត ពោជ្ឈង្គា អរិយោ អដ្ឋង្គិកោ មគ្គោ ខ ៥ អាយតនៈ១២ ធាតុ ១៨ សច្ចៈ៤ ឥន្ទ្រិយ២២បដិច្ចសមុប្បាទ សតិប្បដ្ឋាន៤ សម្មប្ប-

[1] ក្នុងអភិធម្មបិដក ជា អសង្គហិតំ មិនមាន តិ ទេ ។

*ធាន៤ ឥទ្ធិបាទ៤ ឈាន៤ អប្បមញ្ញា៤ ឥន្ទ្រិយ ៥ ពល៥ ពោជ្ឈង្គ៧ មគ្គមានអង្គ៨ ជាមគ្គដ៏ប្រសើរ*

ផស្សោ វេទនា សញ្ញា ចេតនា ចិត្តំ អធិមោក្ខោ មនសិការោ

*ផស្សៈ វេទនា សញ្ញា ចេតនា ចិត្ត ការជឿស៊ប់ ការធ្វើទុកក្នុងចិត្ត*

តីហិ សង្គហោ តីហិ អសង្គហោ ចតូហិ សម្បយោគោ ចតូហិ វិប្បយោគោ សភាគោ វិសភាគោ សព្វាបិ ធម្មសង្គណិ ធាតុកថាយ មាតិកា *ការសង្គ្រោះដោយបទ(១)៣ ការមិនសង្គ្រោះដោយបទ៣ ការប្រកបដោយបទ៤ការប្រាសចេញចាកបទ(២)៤- ធម៌មានចំណែកស្មើគ្នា ទីធម៌មានចំណែកមិនស្មើគ្នា ធម្មសង្គណីទាំងអស់ជាមាតិកានៃធាតុកថា ។*

(នយមាតិកាទិ បញ្ចវីសតិ វិភត្តំ ធាតុកថាបករណំ នាម សមត្តំ *(នេះឈ្មោះជាមាតិកា) មាននយមាតិកាជាដើម; បករណ៍ឈ្មោះធាតុកថា ដែលលោកចែកហើយដោយចំណែក៥ប្រការចប់តែប៉ុណ្ណោះ) ។*

## បុគ្គលបញ្ញត្តិ

*ក្នុងបាលី*

(តទនន្តរំ បុគ្គលបញ្ញត្តិប្បករណំ នាមេសា *លំដាប់អំពី*

---

១- [illegible]

បទណៈឈ្មោះកុសលាធម្មានោះមក យើងនឹងសូត្របទណៈឈ្មោះបុគ្គល-បញ្ញត្តិ ឯបទណៈឈ្មោះបុគ្គលបញ្ញត្តិនោះគឺ )

ឆ បញ្ញត្តិយោ(១) ខន្ធបញ្ញត្តិ អាយតនបញ្ញត្តិ ធាតុបញ្ញត្តិ សច្ចបញ្ញត្តិ ឥន្ទ្រិយបញ្ញត្តិ បុគ្គលបញ្ញត្តិ បញ្ញត្តិ ៦ ប្រការ(២) គឺ ខន្ធបញ្ញត្តិ ១ អាយតនបញ្ញត្តិ ១ ធាតុបញ្ញត្តិ ១ សច្ចបញ្ញត្តិ ១ ឥន្ទ្រិយបញ្ញត្តិ ១ បុគ្គលបញ្ញត្តិ ១

កិត្តាវតា ខន្ធានំ ខន្ធបញ្ញត្តិ ខន្ធបញ្ញត្តិ របស់ខន្ធទាំងឡាយ មានប៉ុន្មានយ៉ាង ?

យាវតា បញ្ចក្ខន្ធា រូបក្ខន្ធោ វេទនាក្ខន្ធោ សញ្ញាក្ខន្ធោ សង្ខារក្ខន្ធោ វិញ្ញាណក្ខន្ធោ ខន្ធទាំងឡាយ ៥ គឺ រូបខន្ធ១ វេទនាខន្ធ សញ្ញាខន្ធ១ សង្ខារខន្ធ១ វិញ្ញាណខន្ធ១ ដោយកំណត់មានប្រមាណឯណា

ឯត្តាវតា ខន្ធានំ ខន្ធបញ្ញត្តិ ខន្ធបញ្ញត្តិ របស់ខន្ធទាំងឡាយ ដោយកំណត់ មានប្រមាណប៉ុណ្ណោះ

កិត្តាវតា អាយតនានំ អាយតនបញ្ញត្តិ អាយតនបញ្ញត្តិ របស់អាយតនៈទាំងឡាយ មានប៉ុន្មានយ៉ាង ?

---

១– ឆ បញ្ញត្តិយោ នេះមានក្នុងអភិធម្មបិដក ។

២– ប្រែថា ការតែងតាំង, ការសំដែង, ការប្រកាស ការតាំងទុក ។

យាវតា ទ្វាទសាយតនានិ ចក្ខាយតនំ រូបាយតនំ សោតាយតនំ សទ្ទាយតនំ ឃានាយតនំ គន្ធាយតនំ ជិវ្ហាយតនំ រសាយតនំ កាយាយតនំ ផោដ្ឋព្វាយតនំ មនាយតនំ ធម្មាយតនំ *អាយតនៈ ១២ គឺ ចក្ខាយតនៈ ១ រូបាយតនៈ ១ សោតាយតនៈ ១ សទ្ទាយតនៈ ១ ឃានាយតនៈ ១ គន្ធាយតនៈ ១ ជិវ្ហាយតនៈ ១ រសាយតនៈ ១ កាយាយតនៈ ១ ផោដ្ឋព្វាយតនៈ ១ មនាយតនៈ ១ ធម្មាយតនៈ ១ ដោយកំណត់ មានប្រមាណឯណា*

ឯត្តាវតា អាយតនានំ អាយតនបញ្ញត្តិ *អាយតនបញ្ញត្តិ របស់អាយតនៈទាំងឡាយ ដោយកំណត់ មានប្រមាណប៉ុណ្ណោះ*

កិត្តាវតា ធាតូនំ ធាតុបញ្ញត្តិ *ធាតុបញ្ញត្តិ របស់ធាតុទាំងឡាយ មានប៉ុន្មានយ៉ាង ?*

យាវតា អដ្ឋារស ធាតុយោ ចក្ខុធាតុ រូបធាតុ ចក្ខុវិញ្ញាណធាតុ សោតធាតុ សទ្ទធាតុ សោតវិញ្ញាណធាតុ ឃានធាតុ គន្ធធាតុ ឃានវិញ្ញាណធាតុ ជិវ្ហាធាតុ រសធាតុ ជិវ្ហាវិញ្ញាណធាតុ កាយធាតុ ផោដ្ឋព្វធាតុ កាយវិញ្ញាណធាតុ

មនោធាតុ ធម្មធាតុ មនោវិញ្ញាណធាតុ ធាតុ១៨គឺ ចក្ខុធាតុ១ រូបធាតុ១ ចក្ខុវិញ្ញាណធាតុ១ សោតធាតុ១ សទ្ទធាតុ១ សោតវិញ្ញាណធាតុ១ ឃានធាតុ១ គន្ធធាតុ១ ឃានវិញ្ញាណធាតុ១ ជិវ្ហាធាតុ១ រសធាតុ១ ជិវ្ហាវិញ្ញាណធាតុ១ កាយធាតុ១ ផោដ្ឋព្វធាតុ១ កាយវិញ្ញាណធាតុ១ មនោធាតុ១ ធម្មធាតុ១ មនោវិញ្ញាណធាតុ១ ដោយកំណត់ មានប្រមាណឯណា

ឯត្តាវតា ធាតូនំ ធាតុប្បញ្ញត្តិ ធាតុប្បញ្ញត្តិ របស់ធាតុទាំងឡាយ ដោយកំណត់ មានប្រមាណប៉ុណ្ណោះ

កិត្តាវតា សច្ចានំ សច្ចប្បញ្ញត្តិ សច្ចប្បញ្ញត្តិ របស់សច្ចៈទាំងឡាយ មានប៉ុន្មានយ៉ាង?

យាវតា ចត្តារិ សច្ចានិ ទុក្ខសច្ចំ សមុទយសច្ចំ និរោធសច្ចំ មគ្គសច្ចំ សច្ចៈទាំង៤គឺ ទុក្ខសច្ចៈ១ សមុទយសច្ចៈ១ និរោធសច្ចៈ១ មគ្គសច្ចៈ១ ដោយកំណត់ មានប្រមាណឯណា

ឯត្តាវតា សច្ចានំ សច្ចប្បញ្ញត្តិ សច្ចប្បញ្ញត្តិ របស់សច្ចៈទាំងឡាយ ដោយកំណត់ មានប្រមាណប៉ុណ្ណោះ

កិត្តាវតា ឥន្ទ្រិយានំ ឥន្ទ្រិយបញ្ញត្តិ *ឥន្ទ្រិយបញ្ញត្តិ របស់ឥន្ទ្រិយទាំងឡាយ មានប៉ុន្មានយ៉ាង ?*

យាវតា ពាវីសតិន្ទ្រិយានិ ចក្ខុន្ទ្រិយំ សោតិន្ទ្រិយំ ឃានិន្ទ្រិយំ ជិវ្ហិន្ទ្រិយំ កាយិន្ទ្រិយំ មនិន្ទ្រិយំ ឥត្ថិន្ទ្រិយំ បុរិសិន្ទ្រិយំ ជីវិតិន្ទ្រិយំ សុខិន្ទ្រិយំ ទុក្ខិន្ទ្រិយំ សោមនស្សិន្ទ្រិយំ ទោមនស្សិន្ទ្រិយំ ឧបេក្ខិន្ទ្រិយំ សទ្ធិន្ទ្រិយំ វីរិយិន្ទ្រិយំ សតិន្ទ្រិយំ សមាធិន្ទ្រិយំ បញ្ញិន្ទ្រិយំ អនញ្ញាតញ្ញស្សាមីតិន្ទ្រិយំ អញ្ញិន្ទ្រិយំ អញ្ញាតាវិន្ទ្រិយំ *ឥន្ទ្រិយទាំងឡាយ ២២ គឺ ចក្ខុន្ទ្រិយ ១ សោតិន្ទ្រិយ ១ ឃានិន្ទ្រិយ ១ ជិវ្ហិន្ទ្រិយ ១ កាយិន្ទ្រិយ ១ មនិន្ទ្រិយ ១ ឥត្ថិន្ទ្រិយ ១ បុរិសិន្ទ្រិយ ១ ជីវិតិន្ទ្រិយ ១ សុខិន្ទ្រិយ ១ ទុក្ខិន្ទ្រិយ ១ សោមនស្សិន្ទ្រិយ ១ ទោមនស្សិន្ទ្រិយ ១ ឧបេក្ខិន្ទ្រិយ ១ សទ្ធិន្ទ្រិយ ១ វីរិយិន្ទ្រិយ ១ សតិន្ទ្រិយ ១ សមាធិន្ទ្រិយ ១ បញ្ញិន្ទ្រិយ ១ អនញ្ញាតញ្ញស្សាមីតិន្ទ្រិយ ១ អញ្ញិន្ទ្រិយ ១ អញ្ញាតាវិន្ទ្រិយ ១*(១) *ដោយកំណត់ មានប្រមាណឯណា*

ឯត្តាវតា ឥន្ទ្រិយានំ ឥន្ទ្រិយបញ្ញត្តិ *ឥន្ទ្រិយបញ្ញត្តិ*

---

១– តាំងពីចក្ខុន្ទ្រិយរហូតដល់សុខិន្ទ្រិយ ១០ នេះ ជាកាមាវចរ (ប្រព្រឹត្តទៅក្នុងកាម) ពីទុក្ខិន្ទ្រិយដល់បញ្ញិន្ទ្រិយ ៩ នេះជាមិស្សកៈ (ច្របូកច្របល់គ្នា) ឯឥន្ទ្រិយ ៣ ខាងចុងជាលោកុត្តរៈ ។

របស់ទ្រព្យទាំងឡាយ ដោយកំណត់ មានប្រមាណប៉ុណ្ណោះ

កិត្តាវតា បុគ្គលានំ បុគ្គលបញ្ញត្តិ បុគ្គលបញ្ញត្តិ របស់បុគ្គលទាំងឡាយ មានប៉ុន្មានយ៉ាង?

សមយវិមុត្តោ អសមយវិមុត្តោ បុគ្គលអ្នករួចស្រឡះតាមកាលគួរ បុគ្គលអ្នករួចស្រឡះតាមកាលមិនគួរ

កុប្បធម្មោ អកុប្បធម្មោ បុគ្គលអ្នកមានធម៌នៅកំរើកញាប់ញ័រ បុគ្គលអ្នកមានធម៌ មិនកំរើកញាប់ញ័រ

បរិហានធម្មោ អបរិហានធម្មោ បុគ្គលអ្នកមានធម៌សាបសូន្យ បុគ្គលអ្នកមានធម៌ មិនសាបសូន្យ

ចេតនាភព្វោ អនុរក្ខនាភព្វោ បុគ្គលអ្នកគួរដល់នូវសេចក្តីមិនសាបសូន្យដោយចេតនា បុគ្គលអ្នកគួរដល់នូវសេចក្តីមិនសាបសូន្យដោយការរក្សា

បុថុជ្ជនោ គោត្រភូ បុគ្គលជាបុថុជ្ជន បុគ្គលជាគោត្រភូ

ភយូបរតោ អភយូបរតោ បុគ្គលអ្នកវៀរចាកបាបដោយភ័យ បុគ្គលអ្នកវៀរចាកបាប ដោយមិនមានភ័យ

ភព្វាគមនោ អភព្វាគមនោ បុគ្គលអ្នកគួរដល់កិរិយាមកដល់

សម្មត្តនិយាមគឺមគ្គ បុគ្គលមិនចូលដល់កិរិយាមកកាន់សម្មត្តនិយាមគឺមគ្គ

និយតោ អនិយតោ បុគ្គលទៀង បុគ្គលមិនទៀង

បដិបន្នកា ផលេ ឋិតោ បុគ្គលអ្នកប្រតិបត្តិព្រមព្រៀង ដោយមគ្គ បុគ្គលអ្នកឋិតនៅក្នុងផល

សមសីសី ឋិតកប្បី បុគ្គលអ្នកមានធម៌ស្មើគ្នា បុគ្គលអ្នកញុំាងកប្បឲ្យឋិតនៅ

អរិយោ អនរិយោ បុគ្គលជាអរិយៈ បុគ្គលមិនមែនជាអរិយៈ

សេក្ខោ អសេក្ខោ បុគ្គលជាសេក្ខៈ បុគ្គលជាអសេក្ខៈ

នេវសេក្ខោ នាសេក្ខោ បុគ្គលមិនមែនជាសេក្ខៈ បុគ្គលមិនមែនជាអសេក្ខៈ

តេវិជ្ជោ ឆឡភិញ្ញោ បុគ្គលអ្នកបានវិជ្ជា ៣ បុគ្គលអ្នកបានអភិញ្ញា ៦

សម្មាសម្ពុទ្ធោ បច្ចេកសម្ពុទ្ធោ[១] បុគ្គលជាព្រះសម្មាសម្ពុទ្ធ បុគ្គលជាបច្ចេកសម្ពុទ្ធ

ឧភតោភាគវិមុត្តោ បញ្ញាវិមុត្តោ បុគ្គលអ្នករួចស្រឡះ

---

១– ក្នុងភាណវារៈថា បច្ចេកពុទ្ធោ ។

ចាកកិលេសដោយចំណែកទាំងពីរ បុគ្គលអ្នករួចស្រឡះ ចាកកិលេសដោយបញ្ញា

កាយសក្ខី ទិដ្ឋិប្បត្តោ បុគ្គលអ្នកមានកាយជាប់ច្បាស់ បុគ្គលអ្នកសម្រេចហើយដោយសម្មាទិដ្ឋិ

សទ្ធាវិមុត្តោ ធម្មានុសារី បុគ្គលអ្នករួចស្រឡះដោយសទ្ធា បុគ្គលអ្នកប្រព្រឹត្តតាមនូវធម៌

សទ្ធានុសារី សត្តក្ខត្តុបរមោ កោលំកោលោ បុគ្គលអ្នកប្រព្រឹត្តតាមនូវសទ្ធា បុគ្គលអ្នកកើតអស់វារៈ ៧ ដង បុគ្គលអ្នកចេញអំពីត្រកូលទៅកាន់ត្រកូល

ឯកពីជី សកទាគាមី បុគ្គលមានពូជតែមួយគត់ បុគ្គលអ្នកមកកាន់លោកនេះម្តងទៀត

អនាគាមី អន្តរាបរិនិព្វាយី បុគ្គលមិនមកកាន់លោកនេះទៀត បុគ្គលបរិនិព្វានកាលពាក់កណ្តាលអាយុ

ឧបហច្ចបរិនិព្វាយី អសង្ខារបរិនិព្វាយី បុគ្គលអ្នកកន្លងហួសពាក់កណ្តាលអាយុ ទើបបរិនិព្វាន បុគ្គលបរិនិព្វានដោយ ...

មិនបាច់ព្យាយាមទាំង

សសង្ខារបរិនិព្វាយី ឧទ្ធំសោតោ អកនិដ្ឋគាមី បុគ្គលអ្នកបរិនិព្វានដោយព្យាយាមទាំង បុគ្គលមានខ្សែនៃមគ្គទៅខាងលើ ដរាបដល់អកនិដ្ឋ ហើយទើបបរិនិព្វាន

សោតាបន្នោ សោតាបត្តិផលសច្ឆិកិរិយាយ បដិបន្នោ បុគ្គលជាសោតាបន្នៈ បុគ្គលអ្នកប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវសោតាបត្តិផល

សកទាគាមី សកទាគាមិផលសច្ឆិកិរិយាយ បដិបន្នោ បុគ្គលជាសកទាគាមី បុគ្គលអ្នកប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវសកទាគាមិផល

អនាគាមី អនាគាមិផលសច្ឆិកិរិយាយ បដិបន្នោ បុគ្គលជាអនាគាមី បុគ្គលអ្នកប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអនាគាមិផល

អរហា អរហត្តផលសច្ឆិកិរិយាយ បដិបន្នោតិ[១] បុគ្គលជាព្រះអរហន្ត បុគ្គលប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអរហត្តផល ។

(អយំ ខន្ធប្បញ្ញត្តាទិ ឆវិធេន វិភត្តំ បុគ្គលប្បញ្ញត្តិប្បករណំ

---

១– ក្នុងអភិធម្មបិដកភាគធំទេ ក្នុងភាគណាភារៈមាតិកា ។

ឆាម សមត្តិ នេះឈ្មោះជាបញ្ញត្តិ មាននាមបញ្ញត្តិជាដើម; បករណៈឈ្មោះបុគ្គលបញ្ញត្តិ ដែលលោកចែកហើយដោយចំណែក ៦ ប្រការ ចប់តែប៉ុណ្ណេះ ) ។

## កថាវត្ថុ

### គន្ថបាលី

(តទនន្តរំ កថាវត្ថុប្បករណំ ឆាមេតំ លំដាប់អំពីបករណៈឈ្មោះបុគ្គលបញ្ញត្តិនោះមក យើងនឹងសូត្រនូវបករណៈឈ្មោះកថាវត្ថុ ឯបករណៈឈ្មោះកថាវត្ថុនោះនេះ )

បុគ្គលោ ឧបលព្ភតិ សច្ចិកដ្ឋបរមដ្ឋេនាតិ សកវាទី សួរថា សភាវៈ(១) ដែលបណ្ឌិតដឹងថាជាបុគ្គល ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តមឬ ?

អាមន្តា បរវាទី ឆ្លើយថា អើ

យោ សច្ចិកដ្ឋោ បរមដ្ឋោ តតោ សោ បុគ្គលោ ឧប-លព្ភតិ សច្ចិកដ្ឋបរមដ្ឋេនាតិ សកវាទី សួរថា សភាវៈ ឯណា

---

១— ពាក្យថា សភាវៈបានដល់ប្រភេទនៃធម៌ ៥៧ គឺ ខន្ធ ៥ អាយតនៈ១២ ធាតុ១៨ ឥន្ទ្រិយ ២២ ។

*មានអត្ថដ៏ពិត មានអត្ថដ៏ឧត្តម ព្រោះហេតុនោះ សភាវៈនោះដែលបណ្ឌិតដឹងថា ជាបុគ្គលដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តមឬ?*

ន ហេវំ វត្តព្វេ *បរវាទី ឆ្លើយថា អ្នកមិនគួរពោលយ៉ាងនេះទេ*

អាជានាហិ និគ្គហំ ហញ្ចិ បុគ្គលោ ឧបលព្ភតិ សច្ចិកដ្ឋបរមដ្ឋេន តេន វត រេ វត្តព្វេ យោ សច្ចិកដ្ឋោ បរមដ្ឋោ តតោ សោ បុគ្គលោ ឧបលព្ភតិ សច្ចិកដ្ឋបរមដ្ឋេនាតិ

*សកវាទីពោលថា អ្នកចូរដឹងនូវទោសចុះ ប្រសិនបើ សភាវៈដែលបណ្ឌិតដឹងថាជាបុគ្គល ដោយអត្ថដ៏ពិតនិងអត្ថដ៏ឧត្តម ម្នាលអ្នកដ៏ចំរើន ព្រោះហេតុនោះ អ្នកគប្បីពោលថា សភាវៈឯណា មានអត្ថដ៏ពិត និងមានអត្ថដ៏ឧត្តម ព្រោះហេតុនោះ សភាវៈនោះ ដែលបណ្ឌិតដឹងថា ជាបុគ្គល ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តមដែរ*

យំ តត្ថ វទេសិ វត្តព្វេ ខោ បុគ្គលោ ឧបលព្ភតិ សច្ចិកដ្ឋបរមដ្ឋេន នោ ច វត្តព្វេ យោ សច្ចិកដ្ឋោ បរមដ្ឋោ តតោ សោ បុគ្គលោ ឧបលព្ភតិ សច្ចិកដ្ឋបរមដ្ឋេនាតិ មិច្ឆា *បណ្ដាពាក្យទាំង*

*ពីរនោះ អ្នកពោលនូវពាក្យឯណា អ្នកគប្បីពោលពាក្យនោះថា សភាវៈដែលបណ្ឌិតដឹងថាជាបុគ្គល ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្ដម តែអ្នកមិនគួរពោលថា សភាវៈឯណា មានអត្ថដ៏ពិតមានអត្ថដ៏ឧត្ដម ព្រោះហេតុនោះ សភាវៈនោះ ដែលបណ្ឌិតដឹងថាជាបុគ្គល ដោយអត្ថដ៏ពិតនិងអត្ថដ៏ឧត្ដមទេ ពាក្យរបស់អ្នកខុសទេ*

តេ បេ បន វត្តព្វេ យោ សច្ចិកដ្ឋោ បរមត្ថោ តតោ សោ បុគ្គលោ ឧបលព្ភតិ សច្ចិកដ្ឋបរមត្ថេនាតិ នោ វត វេ វត្តព្វេ បុគ្គលោ ឧបលព្ភតិ សច្ចិកដ្ឋបរមត្ថេនាតិ *ប្រសិនបើ អ្នកមិនគប្បីពោលថា សភាវៈឯណាមានអត្ថដ៏ពិត មានអត្ថដ៏ឧត្ដម ព្រោះហេតុនោះ សភាវៈនោះដែលបណ្ឌិតដឹងថាជាបុគ្គល ដោយអត្ថដ៏ពិតនិងអត្ថដ៏ឧត្ដមទេ ម្នាលអ្នកដ៏ចំរើន អ្នកមិនគប្បីពោលថាសភាវៈ ដែលបណ្ឌិតដឹងថាជាបុគ្គលដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្ដមទេ*

យំ តត្ថ វទេសិ វត្តព្វេ ខោ បុគ្គលោ ឧបលព្ភតិ សច្ចិកដ្ឋ-បរមត្ថេន នោ ច វត្តព្វេ យោ សច្ចិកដ្ឋោ បរមត្ថោ តតោ សោ បុគ្គលោ ឧបលព្ភតិ សច្ចិកដ្ឋបរមត្ថេនាតិ មិច្ឆា *បណ្ដាពាក្យទាំងពីរ*

នោះ អ្នកពោលនូវពាក្យឯណា អ្នកគប្បីពោលតែពាក្យនោះជាសភាវៈ ដែលបណ្ឌិតដឹងថាជាបុគ្គល ដោយអត្ថ័ពិតនិងអត្ថដ៏ឧត្តម តែអ្នកមិនគួរពោលថាសភាវៈឯណា មានអត្ថពិត មានអត្ថដ៏ឧត្តម ព្រោះហេតុនោះ សភាវៈនោះ ដែលបណ្ឌិតដឹងថាជាបុគ្គល ដោយអត្ថពិត និងអត្ថដ៏ឧត្តម ទេ ពាក្យរបស់អ្នកខុសទេ ។

អនុលោមបញ្ចកំ ចប់អនុលោមបញ្ចកៈ ។

(សកវាទេ បញ្ចសុត្តសតានិ បរវាទេ បញ្ចសុត្តសតានីតិ សុត្ត. សហស្សំ សមោធានេត្វាន វិភត្តំ កថាវត្ថុប្បករណំ តាម សមត្តំ ចប់បករណៈឈ្មោះកថាវត្ថុ ដែលលោកប្រជុំបញ្ចូលនូវសូត្រ ១០០០ គឺ ៥០០ សូត្រក្នុងសកវាទ ៥០០ សូត្រក្នុងបរវាទ ដែលលោកចែកហើយ ចប់តែប៉ុណ្ណេះ) ។

## យមកៈ

ក្នុងបាលី

(តទនន្តរំ យមកប្បករណំ តាមេតំ លំដាប់អំពីបករណៈ

ឈ្មោះកថាតែនោះមក យើងនឹងសួរ នូវបករណៈ ឈ្មោះយមកៈ ឯចតណៈឈ្មោះយមកៈនោះគឺ )

យេ កេចិ កុសលា ធម្មា សព្វេ តេ កុសលមូលា យេ វា បន កុសលមូលា សព្វេ តេ ធម្មា កុសលា ធម៌ទាំងឡាយឯណានីមួយជាកុសល ធម៌ទាំងអស់នោះ ជាកុសលមូល មួយទៀត ធម៌ទាំងឡាយឯណាជាកុសលមូល ធម៌ទាំងអស់នោះជាកុសល

យេ កេចិ កុសលា ធម្មា សព្វេ តេ កុសលមូលេន ឯកមូលា យេ វា បន កុសលមូលេន ឯកមូលា សព្វេ តេ ធម្មា កុសលា ធម៌ទាំងឡាយឯណានីមួយជាកុសល ធម៌ទាំងអស់នោះ មានមូលតែ ១ ដោយកុសលមូល មួយទៀត ធម៌ទាំងឡាយឯណាមានមូលតែ ១ ដោយកុសលមូល ធម៌ទាំងអស់នោះ ជាកុសល

យេ កេចិ កុសលមូលេន ឯកមូលា ធម្មា សព្វេ តេ កុសលមូលេន អញ្ញមញ្ញមូលា យេ វា បន កុសលមូលេន អញ្ញមញ្ញមូលា សព្វេ តេ ធម្មា កុសលា ធម៌ទាំងឡាយឯណានីមួយ មានមូលតែ ១ ដោយកុសលមូល ធម៌ទាំងអស់នោះជាមូលនៃ

គ្នានឹងគ្នា ដោយកុសលមូល មួយទៀត ធម៌ទាំងឡាយឯណាជាមូល នៃគ្នានឹងគ្នា ដោយកុសលមូល ធម៌ទាំងអស់នោះ ជាកុសល

យេ កេចិ កុសលា ធម្មា សព្វេ តេ កុសលមូលមូលា យេ វា បន កុសលមូលមូលា សព្វេ តេ ធម្មា កុសលា ធម៌ទាំងឡាយឯណានីមួយជាកុសល ធម៌ទាំងអស់នោះជាមូល ពោលគឺកុសលមូល មួយទៀត ធម៌ទាំងឡាយឯណាជាមូល ពោលគឺកុសលមូល ធម៌ទាំងអស់នោះ ជាកុសល

យេ កេចិ កុសលា ធម្មា សព្វេ តេ កុសលមូលេន ឯកមូលមូលា យេ វា បន កុសលមូលេន-ឯកមូលមូលា-សព្វេ តេ ធម្មា កុសលា ធម៌ទាំងឡាយឯណានីមួយជាកុសល ធម៌ទាំងអស់នោះជាមូល គឺមូលតែមួយ ដោយកុសលមូល មួយទៀត ធម៌ទាំងឡាយឯណាជាមូលគឺមូលតែមួយដោយកុសលមូល ធម៌ទាំងអស់នោះជាកុសល

យេ កេចិ កុសលមូលេន ឯកមូលមូលា ធម្មា សព្វេ តេ កុសលមូលេន អញ្ញមញ្ញមូលមូលា យេ វា បន កុសល-មូលេន អញ្ញមញ្ញមូលមូលា សព្វេ តេ ធម្មា កុសលា

ធម៌ទាំងឡាយឯណានីមួយ ជាមូលនឹងមូលតែមួយ ដោយកុសលមូល ធម៌ទាំងអស់នោះ ជាមូលនឹងមូលនៃគ្នានឹងគ្នា ដោយកុសលមូល មួយទៀត ធម៌ទាំងឡាយឯណា ជាមូលនៃគ្នានឹងគ្នា ដោយកុសលមូល ធម៌ទាំងអស់នោះ ជាកុសល

យេ កេចិ កុសលា ធម្មា សព្វេ តេ កុសលមូលកា យេ វា បន កុសលមូលកា សព្វេ តេ ធម្មា កុសលា ធម៌ទាំងឡាយឯណានីមួយជាកុសល ធម៌ទាំងអស់នោះ មានកុសលជាមូល មួយទៀត ធម៌ទាំងឡាយឯណា មានកុសលជាមូល ធម៌ទាំងអស់នោះ ជាកុសល

យេ កេចិ កុសលា ធម្មា សព្វេ តេ កុសលមូលេន ឯកមូលកា យេ វា បន កុសលមូលេន ឯកមូលកា សព្វេ តេ ធម្មា កុសលា ធម៌ទាំងឡាយឯណានីមួយជាកុសល ធម៌ទាំងអស់នោះ មានមូលតែមួយដោយកុសលមូល មួយទៀត ធម៌ទាំងឡាយឯណាមានមូលតែមួយដោយកុសលមូល ធម៌ទាំងអស់នោះ ជាកុសល

យេ កេចិ កុសលមូលេន ឯកមូលកា ធម្មា សព្វេ តេ

កុសលមូលេន អញ្ញមញ្ញមូលកា យេ វា បន កុសលមូលេន អញ្ញមញ្ញមូលកា សព្វេ តេ ធម្មា កុសលា ធម៌ទាំងឡាយឯណានីមួយ មានមូលតែមួយដោយកុសលមូល ធម៌ទាំងអស់នោះ ជាមូលនៃគ្នានឹងគ្នា ដោយកុសលមូល មួយទៀត ធម៌ទាំងឡាយឯណា ជាមូលនៃគ្នានឹងគ្នា ដោយកុសលមូល ធម៌ទាំងអស់នោះ ជាកុសល

យេ កេចិ កុសលា ធម្មា សព្វេ តេ កុសលមូល-មូលកា យេ វា បន កុសលមូលមូលកា សព្វេ តេ ធម្មា កុសលា ធម៌ទាំងឡាយឯណានីមួយជាកុសល ធម៌ទាំងអស់នោះ មានកុសលមូលជាមូល មួយទៀត ធម៌ទាំងឡាយឯណា មានកុសលមូលជាមូល ធម៌ទាំងអស់នោះ ជាកុសល

យេ កេចិ កុសលា ធម្មា សព្វេ តេ កុសលមូលេន ឯកមូល-មូលកា យេ វា បន កុសលមូលេន ឯកមូលមូលកា សព្វេ តេ ធម្មា កុសលា ធម៌ទាំងឡាយឯណានីមួយជាកុសល ធម៌ទាំងអស់នោះ មានមូលគឺមូលតែមួយ ដោយកុសលមូល មួយទៀតធម៌ទាំងឡាយឯណា មានមូលគឺមូលតែមួយ ដោយកុសលមូល ធម៌ទាំងអស់នោះ ជាកុសល

យេ កេចិ កុសលមូលេន ឯកមូលមូលកា ធម្មា សព្វេ តេ កុសលមូលេន អញ្ញមញ្ញមូលមូលកា យេ វា បន កុសលមូលេន អញ្ញមញ្ញមូលមូលកា សព្វេ តេ ធម្មា កុសលាតិ[១] ធម៌ទាំងឡាយឯណានីមួយ មានមូលគឺមូលតែមួយ ដោយកុសលមូល ធម៌ទាំងអស់នោះ មានមូលនៃគ្នានឹងគ្នាជាមូល ដោយកុសលមូល មួយទៀត ធម៌ទាំងឡាយឯណា មានមូលនៃគ្នានឹងគ្នាជាមូល ដោយកុសលមូល ធម៌ទាំងអស់នោះ ជាកុសល ។

មូលំ ហេតុ និទានញ្ច សម្ភវោ បភវេន ច សមុដ្ឋានាហារារម្មណា បច្ចយោ សមុទយេន ចាតិ មូល ១ ហេតុ ១ និទាន ១ សម្ភវៈ ១ បភវៈ ១ សមុដ្ឋាន ១ អាហារ ១ អារម្មណ៍ ១ បច្ច័យ ១ សមុទ័យ ១ ។

( មូលយមកាទិទសយមកប្បដិមណ្ឌិតំ យមកប្បករណំ នាម សមត្តំ បករណ៍ឈ្មោះយមកៈ ដែលប្រដាប់ដោយយមកៈ ១០ មានមូលយមកៈជាដើម ចប់តែប៉ុណ្ណេះ ) ។

---

១– កុសលាតិ នេះមិនមានក្នុងអភិធម្មបិដកទេ ។

# បដ្ឋាន

### ភូមិបាលិ

(តទនន្តរំ មហាបដ្ឋានប្បករណំ តាមេតំ លំដាប់អំពីបករណៈ ២ ឈ្មោះយមកៈនោះមក យើងនឹងសូត្រនូវបករណៈឈ្មោះមហាបដ្ឋាន ឯបករណៈឈ្មោះមហាបដ្ឋាននោះគឺ )

ហេតុប្បច្ចយោ អារម្មណប្បច្ចយោ អធិបតិប្បច្ចយោ

ហេតុប្បច្ច័យ[១] អារម្មណប្បច្ច័យ អធិបតិប្បច្ច័យ

អនន្តរប្បច្ចយោ សមនន្តរប្បច្ចយោ សហជាតប្បច្ចយោ

អនន្តរប្បច្ច័យ សមនន្តរប្បច្ច័យ សហជាតប្បច្ច័យ

អញ្ញមញ្ញប្បច្ចយោ និស្សយប្បច្ចយោ ឧបនិស្សយប្បច្ចយោ

អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ ឧបនិស្សយប្បច្ច័យ

បុរេជាតប្បច្ចយោ បច្ឆាជាតប្បច្ចយោ អាសេវនប្បច្ចយោ

បុរេជាតប្បច្ច័យ បច្ឆាជាតប្បច្ច័យ អាសេវនប្បច្ច័យ

---

១– បច្ច័យទាំង ២៤នេះ ប្រែចេញសព្ទទៅទៀតមិនទេ ព្រោះតែប្រែអែបទៅតាមរូបភាសាដើមវិញ ព្រោះបច្ច័យទាំងនេះ មានសេចក្ដីពិស្ដារក្រៃពេក នឹងព្រះសោបយកសេចក្ដីឡើវិញមិនបាន បើចង់ដឹងសេចក្ដីពិសារ សូមមើលអភិធម្មបិដកត្រង់បដ្ឋានឆ័យផងចុះ ។

កម្មប្បច្ចយោ វិបាកប្បច្ចយោ អាហារប្បច្ចយោ *កម្មប្បច្ច័យ វិបាកប្បច្ច័យ អាហារប្បច្ច័យ*

ឥន្ទ្រិយប្បច្ចយោ ឈានប្បច្ចយោ មគ្គប្បច្ចយោ *ឥន្ទ្រិយ-ប្បច្ច័យ ឈានប្បច្ច័យ មគ្គប្បច្ច័យ*

សម្បយុត្តប្បច្ចយោ វិប្បយុត្តប្បច្ចយោ អត្ថិប្បច្ចយោ *សម្បយុត្តប្បច្ច័យ វិប្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ*

នត្ថិប្បច្ចយោ វិគតប្បច្ចយោ អវិគតប្បច្ចយោ *នត្ថិប្បច្ច័យ វិគតប្បច្ច័យ អវិគតប្បច្ច័យ ។*

តិកញ្ច បដ្ឋានវរំ ទុកុត្តមំ ទុកតិកញ្ចេវ តិកទុកញ្ច តិកតិកញ្ចេវ ទុកទុកញ្ច ឆ អនុលោមម្ហិ នយា សុគម្ភីរា *ន័យតាំងឡាយ ៦ គឺតិក[១] បដ្ឋានដ៏ប្រសើរ ១ ទុក[២] បដ្ឋានដ៏ឧត្តម ១ ទុកតិក[៣] បដ្ឋាន ១ តិកទុក[៤] បដ្ឋាន ១ តិកតិក[៥] បដ្ឋាន ១ ទុកទុក[៦] បដ្ឋាន ១ ជាន័យដ៏ជ្រៅ ក្នុងអនុលោម*

---

១– តិកៈ មាន ២២ មានកុសលត្តិកៈជាដើម ។ ២– ទុកៈមាន ១០០ មានហេតុទុកៈជាដើម ។ ៣– យកតិកៈ ២២ មកបញ្ចូលក្នុងទុកៈ ១០០ ។ ៤– យក ទុកៈ ១០០ មកបញ្ចូលក្នុងតិកៈ ២២ ។ ៥– យក តិកៈ ២២ មកបញ្ចូលក្នុងតិកៈ ២២ ។ ៦– យក ទុកៈ ១០០ មកបញ្ចូលក្នុងទុកៈ ១០០ ។

តិកញ្ច បដ្ឋានវរំ ទុកុត្តមំ ទុកតិកញ្ចេវ តិកទុកញ្ច
តិកតិកញ្ចេវ ទុកទុកញ្ច ឆ បច្ចនីយម្ហិ នយា សុគម្ភីរា

ន័យទាំងឡាយ ៦ គឺ តិកបដ្ឋានដ៏ប្រសើរ ១ ទុកបដ្ឋានដ៏ឧត្តម ១ ទុក-តិកបដ្ឋាន ១ តិកទុកបដ្ឋាន ១ តិកតិកបដ្ឋាន ១ ទុកទុកបដ្ឋាន ១ ជាន័យដ៏ជ្រៅ ក្នុងបច្ចនីយៈ

តិកញ្ច បដ្ឋានវរំ ទុកុត្តមំ ទុកតិកញ្ចេវ តិកទុកញ្ច
តិកតិកញ្ចេវ ទុកទុកញ្ច ឆ អនុលោមបច្ចនីយម្ហិ នយា សុគម្ភីរា

ន័យទាំងឡាយ ៦ គឺតិកបដ្ឋានដ៏ប្រសើរ១ ទុកបដ្ឋានដ៏ឧត្តម១ ទុកតិក-បដ្ឋាន ១ តិកទុកបដ្ឋាន ១ តិកតិកបដ្ឋាន ១ ទុកទុកបដ្ឋាន ១ ជាន័យដ៏ជ្រៅ ក្នុងអនុលោមបច្ចនីយៈ

តិកញ្ច បដ្ឋានវរំ ទុកុត្តមំ ទុកតិកញ្ចេវ តិកទុកញ្ច
តិកតិកញ្ចេវ ទុកទុកញ្ច ឆ បច្ចនីយានុលោមម្ហិ នយា សុគម្ភីរាតិ

ន័យទាំងឡាយ ៦ គឺ តិកបដ្ឋានដ៏ប្រសើរ ១ ទុកបដ្ឋានដ៏ឧត្តម ១ ទុកតិកបដ្ឋាន ១ តិកទុកបដ្ឋាន ១ តិកតិកបដ្ឋាន ១ ទុកទុកបដ្ឋាន ១ ជាន័យដ៏ជ្រៅ ក្នុងបច្ចនីយានុលោម ។

(ចតុវីសតិវសេន អយំ សមន្តប្បដ្ឋានប្បករណវណ្ណនា និដ្ឋិតា

ការពណ៌នានូវសមន្តប្បដ្ឋានប្បករណៈនេះដោយអំណាចនៃបដ្ឋាន ២៤

ចប់តែប៉ុណ្ណោះ ) ។ *

(ចប់សត្តប្បករណាភិធម្មត្រឹមប៉ុណ្ណោះ)

## តិរោកុឌ្ឌកណ្ឌគាថា(•)

តិរោកុឌ្ឌេសុ តិដ្ឋន្តិ សន្ធិសិង្ឃាដកេសុ ច

ទ្វារពាហាសុ តិដ្ឋន្តិ អាគន្ត្វាន សកំ ឃរំ

ពួកប្រេតទាំងឡាយមកហើយ កាន់ផ្ទះនៃញាតិដោយគិតថា ផ្ទះរបស់ខ្លួន រមែងឈរ នៅក្រៅជញ្ជាំងទាំងឡាយខ្លះ នៅផ្លូវបែក ជា ៤ និងផ្លូវបែកជា៣ ទាំងឡាយខ្លះ ជិតទ្វារក្រុងនិងទ្វារផ្ទះទាំងឡាយខ្លះ

បហុតេ អន្នបានម្ហិ ខជ្ជភោជ្ជេ ឧបដ្ឋិតេ កាល បាយនិងទឹក និងបង្អែម និងចំអាបចំណីគ្រាន់ ដែលពួកញាតិចូលទៅតាំងទុកហើយ

ន តេសំ កោចិ សរតិ សត្តានំ កម្មបច្ចយា

ញាតិណាមួយ មិនដែលរឭកពួកទាំងឡាយនោះ ព្រោះកម្មរបស់សត្វទាំងឡាយជាបច្ច័យ

ឯវំ ទទន្តិ ញាតីនំ យេ ហោន្តិ អនុកម្បកា

សុចិំ បណីតំ កាលេន កប្បិយំ បានភោជនំ

---

•– បកប្រែតាមសៀវភៅ អនុមោទនវិធី ។

ញាតិទាំងឡាយឯណា តែងអនុគ្រោះ ញាតិទាំងឡាយនោះ រមែងចុះចូលសម្រេចនូវទីកន្លែងគោដ្ឋនៃដំបងដ៏ប្រសើរ ជារបស់គួរគោរពតាល ដល់ញាតិទាំងឡាយ ជាអ្នកចេះរលឹកនេះទៅហើយនោះ យ៉ាងនេះថា

ឥទំ វោ ញាតីនំ ហោតុ សុខិតា ហោន្តុ ញាតយោ

ទាននេះ ចូរមានដល់ញាតិទាំងឡាយ សូមញាតិទាំងឡាយ ចូរជាអ្នកដល់នូវសេចក្តីសុខ

តេ ច តត្ថ សមាគន្ត្វា ញាតិបេតា សមាគតា ពពួកប្រេត ជាញាតិទាំងឡាយនោះ មកប្រជុំគ្នា ហើយក្នុងកន្លែង ដែលឲ្យទាននោះ ជាអ្នកមកហើយដោយបំណងល្អ

បហូតេ អន្នបានម្ហិ សក្កច្ចំ អនុមោទរេ កាលបើបាយ បាយទឹកដ៏ល្មមគ្រាន់ ក៏គប្បីអនុមោទនាដោយគោរពថា

ចិរំ ជីវន្តុ នោ ញាតី យេសំ ហេតុ លភាមសេ យើងទាំងឡាយបានសម្បត្តិនេះ ព្រោះហេតុនៃញាតិទាំងឡាយឯណា សូមញាតិទាំងឡាយនោះ របស់យើងទាំងឡាយ ចូររស់នៅយឺនយូរ

អម្ហាកញ្ច កតា បូជា ក៏បូជាដែលញាតិទាំងឡាយធ្វើហើយដល់

យើងទាំងឡាយ

ទាយកា ច អនិប្ផលា ឯទាយកគឺអ្នកឲ្យទានក៏មិនឥតផល

ន ហិ តត្ថ កសី អត្ថិ កសិកម្មគឺធ្វើស្រែចំការក៏មិន
មានក្នុងភូមិនៃប្រេតនោះ

គោរក្ខេត្ថ ន វិជ្ជតិ គោរក្ខកម្មគឺការរក្សាគោក៏មិនមានក្នុងភូមិ
នៃប្រេតនោះ

វណិជ្ជា តាទិសី នត្ថិ ពាណិជ្ជកម្មគឺការជួញដែលជាហេតុបាន
សម្បត្តិដូច្នោះ ក៏មិនមាន

ហិរញ្ញេន កយាកយំ មិនមានការលក់ទិញផ្លាស់ប្តូរដោយប្រាក់

ឥតោ ទិន្នេន យាបេន្តិ បេតា កាលកតា តហិំ បុគ្គលទាំង
ឡាយ ធ្វើកាលកិរិយាទៅកើតជាប្រេត រមែងញាំងអត្តភាពឲ្យប្រព្រឹត្តទៅ
ក្នុងប្រេតវិស័យនោះ ដោយផលទាន ដែលញាតិឲ្យហើយអំពីលោកនេះ ៕

ឧណ្ណតេ ឧទកំ វុដ្ឋំ យថា និន្នំ បវត្តតិ
ឯវមេវ ឥតោ ទិន្នំ បេតានំ ឧបកប្បតិ
ទឹកធ្លាក់ចុះក្នុងទីទួល រមែងហូរទៅកាន់ទីទំនាប ដូចម្តេចមិញ

*ទានដែលបុគ្គលឲ្យហើយអំពីលោកនេះ រមែងសម្រេចផលដល់ប្រេត ទាំងឡាយ ដូច្នោះដែរ*

យថា វារិវហា បូរា បរិបូរេន្តិ សាគរំ
ឯវមេវ ឥតោ ទិន្នំ បេតានំ ឧបកប្បតិ

*ជ្រលងផ្ទុកទឹកទាំងឡាយមានទន្លេធំនិងស្ទឹងជាដើម រមែងញ៉ាំងសាគរ ឲ្យពេញព្រៀបដូចម្ដេចមិញ ទានដែលបុគ្គលឲ្យហើយអំពីលោកនេះ រមែងសម្រេចផលដល់ប្រេតទាំងឡាយដូច្នោះដែរ*

អទាសិ មេ អកាសិ មេ ញាតិមិត្តា សខា ច មេ
បេតានំ ទក្ខិណំ ទជ្ជា បុព្វេ កតមនុស្សរំ

*បុគ្គលកាលរលឹកឃើញនូវឧបការគុណ ដែលលោកធ្វើទុកដល់ខ្លួនក្នុង កាលមុនថា អ្នកនេះបានឲ្យរបស់នេះដល់អញ អ្នកនេះបានធ្វើគុណនេះ ដល់អញ ជនទាំងឡាយនេះ ជាញាតិមិត្រនិងជាសម្លាញ់របស់អញ ដូច្នេះហើយ គួរឲ្យទក្ខិណាទាន ដើម្បីប្រេតទាំងឡាយ*

ន ហិ រុណ្ណំ វា សោកោ វា យាញ្ញា បរិទេវនា *ការ*

*យំ ក្តី ការសោកសៅ ក្តីការខ្សឹកខ្សួលដទៃៗ មិនមានប្រយោជន៍ទៀប*

ន តំ បេតានមត្ថាយ ធ្វើដូច្នេះក៏បានជាប្រយោជន៍ដល់ប្រេត
ទាំងឡាយគ្មាន

ឯវំ តិដ្ឋន្តិ ញាតយោ ញាតិទាំងឡាយ រមែងស្ថិតនៅឥត
បានផលបានឲ្យយ៉ាងនេះ

អយញ្ច ខោ ទក្ខិណា ទិន្នា បើទក្ខិណាទានដែលបុគ្គល
បានឲ្យហើយនេះឯង

សង្ឃម្ហិ សុប្បតិដ្ឋិតា ជាទានដែលតម្កល់នៅល្អហើយក្នុងសង្ឃ

ទីឃរត្តំ ហិតាយស្ស ឋានសោ ឧបកប្បតិ ទក្ខិណាទាន
នោះ រមែងចូលទៅសម្រេចតាមស្ថាន ដើម្បីជាប្រយោជន៍ដល់ប្រេត
ទាំងនោះ អស់កាលជាយូរអង្វែង

សោ ញាតិធម្មោ ច អយំ និទស្សិតោ ក៏ញាតិធម៌
នេះ អ្នកបានសំដែងជាបែបយ៉ាងនេះហើយ

បេតាន បូជា ច កតា ឧឡារា ការបូជាដ៏ថ្លៃថ្លាចំពោះ
ដល់ប្រេតទាំងឡាយ គឺអ្នកបានធ្វើហើយ

ពលញ្ច ភិក្ខូនមនុប្បទិន្នំ កម្លាំងកាយនៃភិក្ខុទាំងឡាយ

ឈ្មោះថាអ្នកបានបំពេញឲ្យហើយ

តុម្ហេហិ បុញ្ញំ បសុតំ អនប្បកន្តិ បុណ្យគឺអ្នកសន្សំទុកហើយ មិនមែនតិចតួចទេ ។

---

យទិ ហីនេ គតោ ឋានេ កាយទុច្ចរិតេន វា បើ(ញាតិណាមួយ) ទៅកើតក្នុងទីដ៏ថោកទាប ព្រោះកាយទុច្ចរិតក្តី (វចីទុច្ចរិតក្តី មនោទុច្ចរិតក្តី)

ឥមិនា បុញ្ញតេជេន តម្ហា ឋានា បមុញ្ចតុ ក៏សូមឲ្យរួចរំដោះចាកទី (ដ៏ថោកទាប) នោះ ដោយតេជះគុណបុណ្យនេះ

យទិ ទេវបុរេ រម្មេ វិមានេ រតនសោភិតេ ថ្វីបើទៅកើតក្នុងទេវបុរី ជាវិមានសួរគ៌ាល័យ ដែលជាឋានមានលំអដោយរតនៈ (ផ្សេងៗ) ស្រាប់ហើយ ។

ឥមិនា បុញ្ញតេជេន ភិយ្យោ ភិយ្យោ បវឌ្ឍតុ ក៏សូមឲ្យរឹងរឹតតែចំរើនជាភិយ្យោភាព ដោយតេជះគុណបុណ្យនេះ

ឯវំ មហិទ្ធិយា ឯសា យទិទំ បុញ្ញសម្បទា បុញ្ញសម្បទា គឺគុណជាតិជាហេតុផលព្រមគឺបុណ្យឯណា បុញ្ញសម្បទានេះ មានឫទ្ធិធំក្រៃលែង ដោយប្រការយ៉ាងនេះ

តស្មា ធីរា បសំសន្តិ បណ្ឌិតា កតបុញ្ញតំ ព្រោះហេតុនោះ បណ្ឌិតទាំងឡាយ អ្នកមានប្រាជ្ញា រមែងសរសើរនូវភាពនៃបុគ្គលអ្នកមានបុណ្យធ្វើទុកហើយ

សុខោ វិបាកោ បុញ្ញានំ ផលរបស់បុណ្យទាំងឡាយ រមែងនាំមកនូវសេចក្តីសុខ

អធិប្បាយោ សមិជ្ឈតិ សេចក្តីប្រាថ្នា រមែងសម្រេច

ខិប្បញ្ច បរិយោសានេ និព្វានំ សមធិគច្ឆតិ ម្យ៉ាងទៀត ក្នុងកាលជាទីបំផុត បុគ្គលរមែងបាននូវព្រះនិព្វានដ៏ឆាប់រហ័ស

យោ ភាជនសហស្សេហិ បូរណំ វរភោជនំ

ទទេយ្យាបរិមាណានំ ឯកបត្តម្បិ តាលភេ

ពុទ្ធប្បាទេ សារីបុត្តោ យេ បញ្ញោ អគ្គសាវកា

បុគ្គលគប្បីឲ្យនូវភោជន ដ៏ពេញដោយភាជនៈ មួយពាន់ ចំនួនបាន

ស្មើនឹងគោដនមួយបាត្រ ដែលគេបានឲ្យហើយ ដល់ព្រះសារីបុត្ត នឹងពួកអគ្គសាវកដទៃ ក្នុងពុទ្ធុប្បាទ (នេះ) ដែលមានគុណប្រមាណមិនបាន

បត្តប្បានុភាវេន មាតាបិតា បមុញ្ចរេ

(ព្រោះហេតុនោះ) បានជាមាតានឹងបិតា រមែងរួច (ចាកទីដ៏ថោកទាប) ដោយអានុភាពនៃបាយដែលពេញក្នុងបាត្រ ។

ចប់

---

## បដិច្ចសមុប្បាទ

អវិជ្ជាបច្ចយា សង្ខារា សង្ខារទាំងឡាយកើតមាន ព្រោះអវិជ្ជាជាបច្ច័យ

សង្ខារប្បច្ចយា វិញ្ញាណំ វិញ្ញាណកើតមាន ព្រោះសង្ខារជាបច្ច័យ

វិញ្ញាណប្បច្ចយា នាមរូបំ នាមរូបកើតមាន ព្រោះវិញ្ញាណជាបច្ច័យ

នាមរូបប្បច្ចយា សឡាយតនំ អាយតនៈ ៦ កើតមាន ព្រោះនាមរូបជាបច្ច័យ

សឡាយតនប្បច្ចយា ផស្សោ ផស្សៈកើតមាន ព្រោះអាយតនៈ ៦ ជាបច្ច័យ

ផស្សប្បច្ចយា វេទនា *វេទនាកើតមាន ព្រោះផស្សៈជាបច្ច័យ*

វេទនាបច្ចយា តណ្ហា *តណ្ហាកើតមាន ព្រោះវេទនាជាបច្ច័យ*

តណ្ហាបច្ចយា ឧបាទានំ *ឧបាទានកើតមាន ព្រោះតណ្ហាជាបច្ច័យ*

ឧបាទានប្បច្ចយា ភវោ *ភពកើតមាន ព្រោះឧបាទានជាបច្ច័យ*

ភវប្បច្ចយា ជាតិ *ជាតិកើតមាន ព្រោះភពជាបច្ច័យ*

ជាតិប្បច្ចយា ជរាមរណំ *ជរាមរណៈកើតមាន ព្រោះជាតិជាបច្ច័យ*

សោកបរិទេវទុក្ខទោមនស្សុបាយាសា សម្ភវន្តិ *សេចក្ដីសោក ក្ដាយសេចក្ដីខ្សឹកខ្សួល សេចក្ដីលំបាកកាយ លំបាកចិត្ត និងសេចក្ដីចង្អៀតចង្អល់ចិត្ត ក៏កើតមានព្រម ៗ*

ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស សមុទយោ ហោតិ *ការកើតឡើងព្រមនៃកងទុក្ខទាំងអស់នុ៎ះ រមែងមានយ៉ាងនេះឯង ៗ*

អវិជ្ជាយ ត្វេវ អសេសវិរាគនិរោធា សង្ខារនិរោធោ *ការរលត់នៃសង្ខារ ព្រោះរលត់នៃអវិជ្ជាឥតសេសសល់*

សង្ខារនិរោធា វិញ្ញាណនិរោធោ *ការរលត់វិញ្ញាណព្រោះរលត់សង្ខារ*

វិញ្ញាណនិរោធា នាមរូបនិរោធោ *ការរលត់នាមរូប ព្រោះ*

រលត់វិញ្ញាណ

នាមរូបនិរោធា សឡាយតននិរោធោ ការរលត់អាយតនៈ៦ ព្រោះរលត់នាមរូប

សឡាយតននិរោធា ផស្សនិរោធោ ការរលត់ផស្សៈ ព្រោះរលត់អាយតនៈ ៦

ផស្សនិរោធា វេទនានិរោធោ ការរលត់វេទនា ព្រោះរលត់ផស្សៈ

វេទនានិរោធា តណ្ហានិរោធោ ការរលត់តណ្ហា ព្រោះរលត់វេទនា

តណ្ហានិរោធា ឧបាទាននិរោធោ ការរលត់ឧបាទាន ព្រោះរលត់តណ្ហា

ឧបាទាននិរោធា ភវនិរោធោ ការរលត់ភព ព្រោះរលត់ឧបាទាន

ភវនិរោធា ជាតិនិរោធោ ការរលត់ជាតិ ព្រោះរលត់ភព

ជាតិនិរោធា ជរាមរណំ ជរាមរណៈរលត់ ព្រោះរលត់ជាតិ

សោកបរិទេវទុក្ខទោមនស្សុបាយាសា និរុជ្ឈន្តិ សេចក្តីសោកស្តាយ សេចក្តីខ្សឹកខ្សួល សេចក្តីលំបាកកាយ លំបាកចិត្ត និងសេចក្តីចង្អៀតចង្អល់ចិត្ត ក៏រលែងកើតទៅ ។

ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស និរោធោ ហោតិ

*ការរលត់ទៅនៃគំនរទុក្ខទាំងអស់នុ៎ះ រមែងមានយ៉ាងនេះឯង ។*

បឋមពុទ្ធវចនៈ

អនេកជាតិសំសារំ សន្ធាវិស្សំ អនិព្វិសំ

គហការំ គវេសន្តោ ទុក្ខា ជាតិ បុនប្បុនំ

*កាលតថាគតមិនទាន់បានជួបប្រទះ ( នូវពោធិញ្ញាណ ) រវល់តែស្វែងរកនូវជាងផ្ទះគឺតណ្ហា អ្នកធ្វើនូវផ្ទះគឺអត្តភាពហើយអន្ទោលទៅអស់សំសារមានជាតិមិនតែមួយ ជាតិគឺកិរិយាកើតរឿយ ៗ រមែងនាំមកនូវសេចក្ដីទុក្ខ*

គហការក ទិដ្ឋោសិ បុន គេហំ ន កាហសិ

សព្វា តេ ផាសុកា ភគ្គា គហកូដំ វិសង្ខតំ

*ម្នាលជាងផ្ទះគឺតណ្ហា (ឥឡូវនេះ) តថាគតបានឃើញអ្នកច្បាស់ហើយ អ្នកនឹងធ្វើនូវផ្ទះគឺអត្តភាព (នេះ) ឲ្យតថាគតទៀតពុំបានឡើយ ឆ្អឹងជំនីរគឺកិលេសទាំងអស់របស់អ្នក តថាគតបានបំបាក់ចោលហើយ ទាំងកំពូលនៃផ្ទះគឺអវិជ្ជារបស់អ្នក តថាគតក៏បានកំចាត់បង់ហើយ*

វិសង្ខារគតំ ចិត្តំ តណ្ហានំ ខយមជ្ឈគា *ចិត្តរបស់តថាគតបាន*

ផលហើយ នូវព្រះនិព្វាន ដែលមានសង្ខារទៅប្រាសហើយ ក៏ជាអ្នក
បានផលហើយនូវព្រះអរហត្ត គឺការអស់ទៅនៃតណ្ហាទាំងឡាយ ។

ចប់

(អនុញ្ញាត លេខ ១៤៤ ថ្ងៃ ៣០-៥-៥៣
តាងហ្វានក្រសួងក្រុកលិខិត
(ប្រទេសកម្ពុជា)

ការផ្សាយសៀវភៅ នេះជា eBook បាន បង្កើតឡើងដោយ

**មូលនិធិខ្មែរសម្រាប់ការសិក្សា និង ករុណាខ្មែរ**

ដើម្បីបម្រើប្រយោជន៍ជាសាធារណៈ ដោយមិនគិតកម្រៃ

ស្កេន ជា eBook ដោយ **សំ ហ៊្សីនី**

កញ្ញា ឆ្នាំ ២០១៥

គាំទ្រដោយ កូនប្រុស ស្រី

លោក ស៊ី ដារា និងលោកស្រី សុន ដាវី ព្រមទាំងលោកស្រី បុប្ផា ដឺឡូប៉ែស

ដើម្បី ឧទិសកុសល ដល់វិញ្ញាណក្ខន្ធ

លោកឪពុក សង្វារ ដឺ ឡូប៉ឺស និងលោកម្ដាយ ឱន សៅខុន

សូមអរគុណ

ខ្ទៅ យុនសំរ៉ង

ប្រធាន

មូលនិធិខ្មែរសម្រាប់ការសិក្សា

www.elibraryofcambodia.org